ព្រឹត្តិប័ត្រ មត៌កខ្មែរ
Morodok Khmer

លេខ ០៣ ឆ្នាំទី ០១ ខែឧសភា គ.ស. ២០១០ - ព.ស. ២៥៥៤






វត្តខេមររង្សី ទីក្រុងសាន់ហូសេ

# អំពីប្រវត្តិសង្ខេប នៃបុណ្យវិសាខបូជា

មាតិការឿង ទំព័រ


- វាសនាខ្មែរក្រោម..............................០៤
- សាវតារនៃព្រះពុទ្ធទាំង៥.................០៦
- ពិធីពូនភ្នំខ្សាច់ នៅពេល.................០៨
- ពិធីអបអរសាទរបុណ្យចូលឆ្នាំ............៩
- មនុស្សមានប្រយោជន៍.....................១២
- ល្បែងប្រជាប្រិយខ្មែរ........................១៣
- ពិធីអុជទៀនរំលឹកវិញ្ញាណក្ខ័ន្ធ..........១៤
- លោកជំទាវ មួរ សុខ ហួរ...................១៦
- អ្នកកាសែតជើងចាស់......................២១
- ទំនាក់ទំនងវវាង................................២៣
- ស្រណោះដីខ្មែរ.................................៣០


ប្រជាពលរដ្ឋខ្មែរ និងជាតិសាសន៍ដទៃៗទៀត ដែលជាអ្នកគោរពប្រតិបត្តិព្រះពុទ្ធសាសនា កាលបើដល់ថ្ងៃ១៥កើត ពេញបូរមី ខែវិសាខ ហើយ ព្រះសង្ឃនិងពុទ្ធបរិស័ទទាំងអស់ តែងតែនាំគ្នាប្រារព្ធពិធីបុណ្យ **វិសាខបូជា** ដើម្បីរំឭកនឹកដល់នក្ខត្តឫក្សទាំងបីគឺ៖ ថ្ងៃដែលព្រះអង្គទ្រង់ប្រសូតិ, ត្រាស់ដឹង និងយាងចូលកាន់បរិនិព្វាន។

• ព្រះពោធិសត្វទ្រង់ប្រសូតិ នៅថ្ងៃសុក្រ ១៥កើត ពេញបូរមី ខែវិសាខ ឆ្នាំច វេលាជិតថ្ងៃត្រង់ ក្រោមដើមរាំងភ្នំក្នុងឧទ្យានដ៏ល្អប្រណិតមួយ ឈ្មោះថា **លុម្ពិនី** ដែលស្ថិតនៅចំព្រំដែននៃនគរទាំងពីរគឺ៖ នគរកបិលពស្តុនិងនគរទេវទហៈ។

នៅពេលព្រះពោធិសត្វប្រសូតិចាកចេញពីព្រះឧទរភ្លាម ព្រះអង្គទ្រង់ប្រថាប់ឈរបែរព្រះភក្ត្រទៅទិសឧត្តរ រួចហើយទ្រង់យាងទៅបាន៧ជំហាន ពន្លឺនូវអភិសវាចាថា« *ខ្លួនអញជាកំពូលនៃ.....* ***(តទៅទំព័រទី៧)***

វត្តខេមររង្សី ក្រុងសាន់ហូស្សេ រដ្ឋកាលីហ្វ័រញ៉ា
1594 Cunningham Ave San Jose, CA 95122
Tel: (408) 923-2166 / 550-5060
http://www.unitedkhmerkrom.org

## លិខិតអញ្ជើញ បុណ្យវិសាខបូជា

យើងខ្ញុំ ព្រះករុណា អាត្មាភាព ជាគណៈកម្មការ អាចារ្យ **វត្តខេមររង្សី** ក្រុងសាន់ហូស្សេ រដ្ឋកាលីហ្វ័រញ៉ា បានមូលមតិគ្នា ប្រារព្ធបុណ្យ **វិសាខបូជា** ដើម្បីរំលឹកនឹកដល់ថ្ងៃនក្ខត្តឫក្សទាំង៣ ដែលព្រះសម្មាសម្ពុទ្ធ **ទ្រង់ប្រសូតិ**, **ត្រាស់ដឹង**, **បរិនិព្វាន** និងពិធីទទួលព្រះអដ្ឋិធាតុ **ព្រះមហាមោគ្គល្លាន**, **ព្រះមហាសារីបុត្រ**, **ព្រះសិម្ពលីថេរ** នៃសាវកព្រះពុទ្ធ តម្កល់ទុកក្នុងវត្ត **ខេមររង្សី** សម្រាប់ពុទ្ធបរិស័ទធ្វើសក្ការៈបូជា និងជាតំណាងពុទ្ធសាសនា។

អាស្រ័យដូចបានចំរើនពរ និងជំរាបជូនខាងលើ អាត្មាភាព យើងខ្ញុំ សូមគោរពអញ្ជើញ លោក លោកស្រី និង ពុទ្ធបរិស័ទជិតឆ្ងាយ មេត្តាចូលរួមញ៉ាំងពិធីបុណ្យវិសាខបូជានេះ ឲ្យបានច្រើនកុះករ ដើម្បីគោរពបូជាថ្ងៃនក្ខត្តឫក្ស និង សុំសេចក្តីសុខ-ចំរើន រួចអនុមោទនាយកផលានិសង្សរៀងៗខ្លួន។

**INVITATION T0 THE VESAK DAY**

On **Vesak Day,** Buddhists around the world commemorate events of significance: The birth, enlightenment and the passing away of Gautama Buddha.

On behalf of the Buddhist monks and committee members, we would like to cordially invite you, your family, and your friends to attend the **Vesak Day** ceremony which will be held at these following dates and location:

**កម្មវិធីបុណ្យ**

### ថ្ងៃសៅរ៍ ទី ០៨ ខែឧសភា ឆ្នាំ២០១០ (Saturday May 08, 2010)

-ពីម៉ោង **8:30AM–9:30AM** ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ ធ្វើពិធីសក្ការៈបូជនីយដ្ឋានទាំង៣។

-ពីម៉ោង 9:30AM–11:00PM និមន្តព្រះសង្ឃទ្រង់បិណ្ឌបាត្រ។

-ពីម៉ោង 11:00PM–12:00PM ពិធីពុទ្ធសាសនកិច្ច និងទេសនាគ្រែពីរ ដោយព្រះមហា **ថាច់ ធឿន** ព្រះចៅអធិការវត្តវេឡុវ័ន រដ្ឋ Alabama និងព្រះតេជគុណ **ច័ន្ទ សុផាត** ប្រធានសម្ព័ន្ធសមណនិស្សិតខ្មែរក្រោម នៅកម្ពុជា។

-ពីម៉ោង 12:00PM–1:00PM ពុទ្ធបរិស័ទជិតឆ្ងាយ ទទួលភោជនាហារ។

-ពីម៉ោង 5:00PM–9:00PM ពិធីទទួលព្រះអដ្ឋិធាតុ នៃសាវកព្រះពុទ្ធ និងចំរើនព្រះបរិត្ត។

### ថ្ងៃអាទិត្យ ទី ០៩ ខែឧសភា ឆ្នាំ២០១០ (Sunday May 09, 2010)

-ពីម៉ោង 9:00AM–1:00PM ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយ និមន្តព្រះសង្ឃទ្រង់បិណ្ឌបាត្រ, ពុទ្ធសាសនកិច្ច, ដង្ហែព្រះសារីរិកធាតុប្រទក្សិណ៣ជុំ និងពិធីនមស្ការបូជនីយស្ថានទាំង៣ ជាកិច្ចឆ្លងកម្មវិធីបុណ្យ។

*បញ្ជាក់៖ នៅក្នុងពិធីបុណ្យ ក៏មានចែកជាធម្មទាន នូវសៀវភៅធម៌ដែលទាក់ទិននឹងការអប់រំនិងរឿងរ៉ាវព្រះពុទ្ធផងដែរ !...*

# មូលហេតុ
## ស្ដីពីការចេញផ្សាយ នៃព្រឹត្តិប័ត្រ មត៌កខ្មែរ

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** នៃពុទ្ធិកសមាគមខ្មែរក្រោម វត្តខេមររង្សី នៅទីក្រុងសាន់ហូសេ្ស នឹងចេញផ្សាយតាមគេហទំព័រ http://www.unitedkhmerkrom.org / http://morodokkhmer2010.wordpress.com និងបោះពុម្ពផ្សាយជារៀងរាល់ខែ ដើម្បីពង្រឹងពង្រីក វិស័យវប្បធម៌, ប្រពៃណី, ទំនៀមទម្លាប់, ភាសា, អក្សរសាស្ត្រជាតិ និងដំណឹងថ្មីៗ ពីសហគមន៍ខ្មែរ នៅក្នុងនិងក្រៅប្រទេស។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ផ្សព្វផ្សាយនូវសកម្មភាពសង្គម, ព័ត៌មានខ្មែរ-អន្តរជាតិ, អប់រំ, សុខភាព, កីឡា, រឿងរ៉ាវប្លែកៗ, សីលធម៌, ទស្សនៈកវី និងពុទ្ធសាសនាជាដើម....។ល។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** យកប្រាសាទព្រះវិហារធ្វើជាសញ្ញា (Logo) ដោយប្រាសាទព្រះវិហារ គឺជាទ្រព្យសម្បត្តិរបស់ជាតិខ្មែរ ហើយអង្គការយូនីស្កូ បានចុះក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក កាលពីថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេបិច ប្រទេសកាណាដា។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ចេញផ្សាយជារៀងរាល់ខែ តាមគេហទំព័រ និងបោះពុម្ពចែកចាយដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០ នេះតទៅ។

សេចក្ដីដូចបានប្រគេន-ជំរាបជូនដំណឹងខាងលើ សូមមិត្តអ្នកអាននៅក្នុងនិងក្រៅប្រទេស ជាពិសេសសហគមន៍ខ្មែរ នៅទីក្រុងសាន់ហូសេ្ស មេត្តាជ្រាបជាព័ត៌មាន និងគាំទ្រនូវដំណឹងថ្មីៗ ពីព្រឹត្តិប័ត្រ **មត៌កខ្មែរ** ដោយសោមនស្សរីករាយ។

*បញ្ជាក់៖ លោក លោកស្រី ផ្សាយពាណិជ្ជកម្មជាមួយ ព្រឹត្តិប័ត្រ មត៌កខ្មែរ សូមទំនាក់ទំនង* Tel: **(408) 923-2166**

ធ្វើនៅទីក្រុងសាន់ហូសេ្ស, ថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០

គណៈកម្មការ **ព្រឹត្តិប័ត្រ មត៌កខ្មែរ**

---

## ព្រឹត្តិប័ត្រមត៌កខ្មែរ

- ព្រះតេគុណ សឹង យ៉ឹង រតនា នាយកការផ្សាយ
- ព្រះតេជគុណ ថាច់ សុរិយា និពន្ធនាយក
- លោក អ៊ុក សុភ័ព្ទ សម្រួលអត្ថបទ
- អ្នកស្រី គីលីន វិនីតា ពាណិជ្ជកម្ម
- លោក កោះ ថុន ពិនិត្យអត្ថបទ
- អ្នកស្រី បៃ សុផានី ផ្សព្វផ្សាយ
- លោក នឹង ស៊ិន ទីប្រឹក្សា

## អាសយដ្ឋានទំនាក់ទំនង

**ព្រឹត្តិប័ត្រ មត៌កខ្មែរ**
**MORODOK KHMER**
1594 Cunningham Ave.
San Jose, CA 95122. U.S.A
E-mail: morodokkhmer2010@gmail.com
Tel: (408) 923-2166/890-8877/550-5050
http://www.unitedkhmerkrom.org

# វាសនាខ្មែរក្រោម

របបគ្រប់គ្រងក្រុងហាណូយនៃបក្សកុម្មុយនិស្តយួន គឺជាចរន្តនយោបាយអយុត្តិធម៌មានមហិច្ឆិតាឈ្លានពានរំលោភសិទ្ធិមនុស្សនិងរើសអើងពូជសាសន៍ដែនដីកម្ពុជាក្រោម ខ្មែរកម្ពុជាក្រោមជាម្ចាស់ស្រុកដោយថ្នាក់ដឹកនាំខ្មែរល្មោភអំណាចស្រវឹងនឹងកាមគុណសម្រស់បុប្ផាពស់វែកយួន បំភ្លេចផលប្រយោជន៍ជាតិរួចបំផ្លាញជាតិខ្លួនឯង និង លក់ឧត្តមគតិទៅឲ្យបរទេសយួនឥតលក្ខខ័ណ្ឌនោះ ទីបំ ផុតជីវិតខ្មែរក្រោមរងទុក្ខឥតល្ហែ។ បន្ទាប់ពីបារាំងបានប្រគល់កម្ពុជាក្រោមឲ្យទៅវៀតណាមធ្វើអាណានិគមបន្តនៅថ្ងៃទី០៤ខែមិថុនាឆ្នាំ ១៩៤៩ ដោយខុសច្បាប់នោះមក រដ្ឋាភិបាលយួនក្រុងហាណូយបានប្រើនយោបាយយ៉ាងឃោរឃៅបែងចែកវណ្ណៈរវាងខ្មែរក្រោមនិងយួន ។

អស់ជាច្រើនទសវត្សរ៍ ដែលក្រុងហាណូយប្រើអំណាចផ្តាច់ការរំលោភសិទ្ធិមនុស្ស និងបំបាត់ពូជសាសន៍ខ្មែរក្រោម ជនជាតិដើមខ្មែរក្រោមត្រូវបានយួនកាប់សម្លាប់ ឆក់ប្លន់ដីធ្លី ធ្វើឃាតព្រះសង្ឃ បំផ្លាញវត្តអារាមធ្វើទារុណកម្មបណ្ឌិត បញ្ញវ័ន្ត និងចាក់ថ្នាំសម្លាប់ ។ល។ អំពើឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនិស្តយួនបែបនេះបានធ្វើឲ្យព្រះសង្ឃ និងជនជាតិដើមខ្មែរក្រោមរស់ទាំងត្រដរ ទាំងទឹក ភ្នែក លេបថ្ម លេបគ្រួស កំព្រារងាដួងចិត្ត តាំងពីអតីតកាលរហូតមកទល់បច្ចុប្បន្ន ។

ទោះបីខ្មែរក្រោមរស់ក្នុងក្រញ៉ាំមាត់ខ្លាយួនក្តី ក៏ទឹកចិត្តនៅតែតស៊ូរើបំរះ ការពារ រក្សានូវវប្បធម៌ ប្រពៃណីទំនៀមទម្លាប់ ភាសា អក្សរសាស្ត្រនិងជំនឿព្រះពុទ្ធសាសនាដោយស្មារតីស្នេហាជាតិយ៉ាងពិតប្រាកដ។

ទង្វើអយុត្តិធម៌ របស់ក្រុងហាណូយបានធ្វើឲ្យប្រជាពលរដ្ឋខ្មែរក្រោមស្លាប់ និងជាប់ពន្ធនាគារទទួលទារុណកម្មឥតស្រាកស្រានពីរបបគ្រប់គ្រងយួន។ ដោយនយោបាយបំបាត់ពូជសាសន៍បែប នេះហើយគឺជាវិបត្តិឬជម្ងឺរីងរៃដេក់ជាប់ ក្នុងបេះដូងខ្មែរក្រោមគ្រប់ស្រទាប់វណ្ណៈ មិនអាចបំភ្លេចបាននូវការឈឺចាប់ខ្លោចផ្សាទាំងនោះបានឡើយ។

ស្រមោលអតីតកាលបានជិតដាមតាមលងប្រជាពលរដ្ឋខ្មែរក្រោមឥតឈប់ឈរ ធ្វើឲ្យខ្មែរក្រោមមួយចំនួនធំបានបង្ខំចិត្តរត់កៀសខ្លួន ចេញពីមាតុភូមិកម្ពុជាក្រោមដ៏មហាសែនស្រណោះ ទៅជ្រកកោនតាមបណ្តាប្រទេសស្រឡាញ់យុត្តិធម៌និង សន្តិភាពនៅជុំវិញពិភពលោកក្នុងនោះមានប្រទេសកម្ពុជាជាដើម ។

មហិច្ឆិតាដ៏ខ្មៅងងឹតរបស់យួនមានបំណងគ្រប់គ្រង ឬធ្វើអាណានិគមទៅលើឥណ្ឌូចិន មានប្រទេសឡាវនិងកម្ពុជាជាដើម។ជាលទ្ធផលនៃ អំពើឈ្លានពានរបស់ខ្មោច ហូ ជី មិញ ទទួលបានសម្រេចជោគជ័យជាស្ថាពរ។ ជាក់ស្តែង បច្ចុប្បន្ន ប្រទេសឡាវត្រូវបានគ្រប់គ្រងដោយស្រមោលក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ។ ចំណែកប្រទេសកម្ពុជា សព្វថ្ងៃក៏ដូចប្រទេសឡាវផងដែរ គឺថ្នាក់ដឹកនាំជាតិមួយចំនួនធំនៃរដ្ឋាភិបាលខ្មែរ ទាំងពុទ្ធចក្រនិងអាណាចក្រត្រូវបានស្ថិតក្រោមបញ្ជាពីក្រុងហាណូយទាំងអស់ ។

ទោះបីបច្ចុប្បន្នយើងឃើញប្រទេសកម្ពុជា មានសិទ្ធិសេរីភាពនិងឯករាជ្យក៏ពិតមែននោះ គឺគ្រាន់ជាសំបកក្រៅតែប៉ុណ្ណោះពោលគឺផ្ទៃក្នុងនៃប្រទេសកម្ពុជាត្រូវបានបក្សកុម្មុយនិស្តក្រុងហាណូយ គ្រប់គ្រងស្ទើទាំងស្រុង។ ទាហរណ៍ជាក់ស្តែង ករណីព្រះតេជព្រះគុណ **ទឹម សា ខន** អតីតព្រះចៅអធិការវត្តភ្នំដិនខាងជើងស្រុក គិរីវង្ស ខេត្តតាកែវ ដែលមានដើមកំណើតជាខ្មែរក្រោមត្រូវបានក្រុមមន្ត្រីសង្ឃ ៧ មករា រួមជាមួយក្រុមអាជ្ញាធរខ្មែរ ដែលឃុបឃិត និង បំរើនយោបាយកុម្មុយនិស្តយួនដាច់ថ្លៃបានចាប់បង្ខំដោះស្បង់ចីវរទាំងកំរោលកាលពី ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៧ កន្លងទៅនេះ ដោយចោទប្រកាន់ ពីធ្វើចលនាឃោសនាបំបែកបំបាក់មិត្តភាពរវាងកម្ពុជាយៀកណាម ....***(តទៅទំព័រទី១៥)***




# ហាងខ្មែរលក់មាស ឡាក់គី
# LUCKY JEWELRY

- មានលក់ពេជ្រ HRD, GIA, IGI គ្រប់មូដ
- មាសសន្លឹក 24K 999, Canada Credit Swiss
- គ្រឿងត្បូង South - Sea Pearl គ្រប់ជំពូក
- មានគ្រឿងអលង្ការនាំចូលថ្មីៗពីបរទេស
- មានរចនាមូដល្អៗទាន់សម័យនិយម
- ទិញចូលមានតម្លៃខ្ពស់
- លក់ចេញមានតម្លៃថោកសមរម្យ
- សូមអញ្ជើញអតិថិជនចូលជាវដោយមេត្រីភាព



- There are vast choices of models for HRD, GIA, IGI diamonds.

* 24K ... 999 flat-carded gold's are available from Canada Credit Swiss.
* All kind availabilities for gems and pearls from South-Sea Pearl.
* Newly imported jewelries from international countries.
* Modernize models are always updated.
* We buy your jewelries with high value offerings.
* We sell our jewelries with low, affordable pricing.
* **Please stop by, and we will guarantee your satisfaction**!

- **ម៉ោងធ្វើការៈ** Mon - Fri: 10:00am - 7:00pm
  Tel: (408) 238-2098

- **2471 Alvin Ave. San Jose, CA 95121**
  មានទទួល Visa, Master Card ៣ខែមិនគិតថ្លៃចុងការ

# មជ្ឈមណ្ឌលខ្មែរថែរក្សាភ្នែក SUNRISE

## Sunrise Medical-Dental Center

•មានវេជ្ជបណ្ឌិតស្ទាត់ជំនាញក្នុងការពិនិត្យភ្នែក។
•មានម៉ាស៊ីនទំនើបអាចវាស់ភ្នែកនិងកាត់កញ្ចក់វ៉ែនតា តាមតំរូវការ។
•មានវេជ្ជបណ្ឌិតនិយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញ។






Phone: (408) 227-6444
Fax: (408) 227-5056
www.kasod.com

DR. KENNETH A. WIENER
DR. STEVEN M. KAS
*Optometrists*

Eye Care/Lasik Consultations

Sunrise Medical-Dental Center
5710 Cahalan Avenue, Bldg. 2 San Jose, CA 95123

5710 Cahalan Avenue, Bldg.2
San Jose, CA 95123
Phone: (408) 227-6444
Fax: (408) 227-5056
www. Kasod.com

# សាវតារនៃព្រះពុទ្ធទាំង៥ព្រះអង្គ

សព្វថ្ងៃនេះប្រជាពលរដ្ឋខ្មែរយើង ជាអ្នកគោរពប្រតិបត្តិព្រះពុទ្ធសាសនា តាំងពីបុរាណកាលមកម្ល៉េះ តែពុទ្ធបរិស័ទនៅមានការសង្ស័យថាព្រះពុទ្ធទាំង៥ព្រះអង្គនោះមានប្រវត្តិយ៉ាងណា?ហើយហេតុអ្វីបានជារូបតំណាងព្រះពុទ្ធនីមួយៗក្រោមរូបភាពជាសត្វទៅវិញ?

**ព្រះពុទ្ធទាំង៥ព្រះអង្គនោះគឺ**

- កកុសន្ធោ តំណាងឱ្យសត្វមាន់
- កោនាគមនោ តំណាងឱ្យសត្វនាគរាជ
- កស្សបោ តំណាងឱ្យសត្វអណ្តើក
- គោតមោ តំណាងឱ្យសត្វគោ
- អរិយមេត្តេយ្យោ តំណាងឱ្យសត្វខ្លាឬរាជសីហ៍

យោងតាមការសិក្សាស្រាវជ្រាវ និង ឯកសារមួយចំនួនបានបញ្ជាក់យ៉ាងច្បាស់ថា ក្នុងអតីតកាលដ៏យូរណាស់មកហើយ ដែលពុំអាចកំណត់ពេលវេលាបាននោះ មានសត្វក្អែកសមួយគូស្រឡាញ់គ្នាខ្លាំងណាស់។ ក្អែកទាំងពីរនោះ បាននាំគ្នាធ្វើសំបុកនៅលើដើមឈើដែលស្ថិតនៅក្បែរឈូងសមុទ្ររួចមកក្អែកញីក៏បានពងចំនួន៥។

ក្អែកទាំងពីរនេះ ខិតខំរក្សាពងទាំង៥នោះដោយយកចិត្តទុកដាក់ជាទីបំផុត តែជាអកុសលថ្ងៃមួយមានខ្យល់ព្យុះសង្ឃរាបានបោកបក់ដើមឈើធ្វើឱ្យសំបុកធ្លាក់ទៅក្នុងសមុទ្របាត់ទៅ ជាហេតុធ្វើឱ្យពងទាំង៥នោះរសាត់ទៅតាមខ្សែទឹកគួរឱ្យរន្ធត់។ ក្អែកទាំងពីរខំហើរម្នីម្នាឆ្លេឆ្លាតាមឆាបយកពងមកវិញ តែមិនបានដូចបំណង ដោយការឈឺចាប់ខ្លោចផ្សាអាឡោះអាល័យនូវពងរបស់ខ្លួនខ្លាំងពេកក៏ក្ស័យជីវិតទៅ។ ក្រោយពីស្លាប់ក្អែកទាំងពីរបានទៅចាប់កំណើតនៅឋានព្រះព្រហ្ម..... ឈ្មោះ «**ពកាមហាព្រហ្ម**» ។

តាមការពិត ពងទាំងនោះ ដែលអណ្តែតនៅលើទឹកពុំមានគ្រោះថ្នាក់អ្វីទេ ព្រោះជាតំណាងតួអង្គនៃព្រះពោធិសត្វ ហើយបានអណ្តែតប្រាសទឹកបញ្ចេញពន្លឺគួរឱ្យគយគន់ ទីបំផុតពងទាំង៥បានបណ្តែតដល់



ព្រះពុទ្ធទាំង៤ព្រះអង្គ និងព្រះអរិយមេត្តេយ្យោមិនទាន់បានត្រាស់

សត្វមាន់ សត្វនាគ សត្វអណ្តើក សត្វគោ និងសត្វខ្លា ស្តេចសត្វទាំង៥ បានរើសយកថែរក្សាហូតដល់ញាស់គ្រប់ៗគ្នា។

ដោយមានឧបនិស្ស័យនឹងព្រះពុទ្ធសាសនានោះ សត្វទាំង៥ ចំរើនវ័យកាលណាក៏បានប្រែក្រឡាទៅជា «មនុស្ស»ហើយបានទៅសាងផ្នួសប្រកបដោយទឹកចិត្តជ្រះថ្លា។ នៅថ្ងៃមួយអ្នកទាំង៥បានឆ្លងកាត់ស្ទឹងមួយ តែពុំអាចឆ្លងកាត់បានដោយស្ទឹងនោះជ្រៅពេកក៏សំរេចចិត្តអង្គុយនៅក្បែរមាត់ស្ទឹង រង់ចាំក្រែងមាននរណាអុំទូកឆ្លងកាត់ ដើម្បីសុំដោយសារឆ្លងទៅកាន់ត្រើយម្ខាងទៀត។ក្នុងខណៈនោះដែរស្រាប់តែមានស្ត្រីម្នាក់ឈ្មោះ «**មយីមយា**» ចែវទូកក្បែរនោះ។

ពេលនោះនាងបានសួរទៅបុរសទាំង៥រូបថា តើហេតុអីពួកអ្នកចង់ទៅត្រើយម្ខាង?

អ្នកទាំង៥បានឆ្លើយតបយ៉ាងប្រញាប់ប្រញាល់ថា ពួកខ្ញុំប្រាថ្នាចង់ត្រាស់ដឹងជាព្រះពុទ្ធ។ នាងក៏ដាក់លក្ខខណ្ឌថា បើដូច្នោះខ្ញុំសូមឱ្យអ្នកទាំង៥យកខ្ញុំធ្វើជាម្តាយ ហើយបុរសទាំងអស់នោះក៏យល់ព្រមភ្លាមដែរ។

យោងតាមដំណើររឿងខាងលើ នាងមយីមយា បានក្លាយខ្លួនជាព្រះមាតារបស់ព្រះពុទ្ធទាំង៥ ក្នុងភទ្ទកប្បនេះ។ ម្យ៉ាងទៀតព្រះពុទ្ធទាំង៥ព្រះអង្គ ក្រោយពីបានត្រាស់ដឹងក៏យកឈ្មោះម្តាយ ដែលថែរក្សាខ្លួនមកប្រើដូចបណ្តាំ។ដូច្នេះបុរសដែល....(**តទៅទំព័រទី១០**)

*(តមកពីទំព័រទី១)* *លោក បុគ្គលដ៏ប្រសើរវិសេសជាង*



ព្រះពោធិសត្វទ្រង់ប្រសូតិ ចាកព្រះឧទរនៃព្រះមាតា

*គេក្នុងលោក ជាចំបងជាងគេទាំងអស់ក្នុងលោក ជាតិនេះគឺជាកំណើតចុងក្រោយបំផុតរបស់អាត្មាអញ។ អំណើះអំពីជាតិនេះទៅអាត្មាអញនឹងមិនកើតទៀតទេ។*

• ព្រះសមណគោតមទ្រង់បានត្រាស់ដឹងមុនពេលព្រះអរុណរះ នៅថ្ងៃពុធ ១៥កើតពេញបូរមី ខែពិសាខ ឆ្នាំរកា ត្រូវនឹងថ្ងៃទី៨ ខែធ្នូ មុនពុទ្ធសករាជ៤៥ឆ្នាំ ក្នុងព្រះជន្មាយុគំរប់៣៥ព្រះវស្សា ក្រោមដើមពោធិព្រឹក្ស។

កាលបានត្រាស់ដឹង នូវព្រះសម្មាសម្ពោធិញ្ញាណរួចហើយ ព្រះសមណគោតម ហាក់មានពន្លឺរស្មីចាំងសាយចេញអំពីព្រះអង្គកាយដែលប្រកបទៅដោយសិរីសោភគ្គសម្បត្តិ ដ៏រុងរឿងក្រៃលែង។ ជំនោរត្រជាក់បក់មករំភើយៗមកប៉ះនឹងស្លឹកពោធិពណ៌ប្រាក់ ក្រោមពន្លឺព្រះចន្ទថ្លាធ្វើឱ្យលាន់ឮសម្លេងរងំ ហាក់បីដូចជាគេប្រគំតន្ត្រីដ៏ពិរោះ។ បុប្ផាជាតិចំរុះពណ៌ត្រូវទឹកសន្សើមរីកស្គុះស្គាយ ចោលសុគន្ធពិដោរក្រអូបសាយចូលមកបូជានិងថ្វាយព្រះពរជ័យចំពោះការត្រាស់របស់ព្រះអង្គនាពេលនោះ។

• ព្រះសមណគោតមបរមគ្រូ ទ្រង់យាងចូលកាន់



ព្រះសម្មាសម្ពុទ្ធយាងចូលកាន់បរិនិព្វាន ក្នុងព្រៃសាលវ័ន

បរិនិព្វាន ក្នុងវេលាពាក់កណ្ដាលអធ្រាត្រ នាថ្ងៃអង្គារពេញបូរមី ខែពិសាខ ឆ្នាំម្សាញ់ ក្នុងព្រៃសាលវ័ន របស់ពួកមល្លក្សត្រ នាក្រុងកុសិនារា។

ពួកមល្លក្សត្រ និងអ្នកក្រុងកុសិនារា បានរៀបចំពិធីបុណ្យឈាបនកិច្ចនៃព្រះសពព្រះសមណគោតម តាមរបៀបស្ដេចចក្រពត្តិ អស់រយៈកាល៦ថ្ងៃ៦យប់។ ព្រះភិក្ខុសង្ឃនិងពួកមហាក្សត្រ សេដ្ឋី គហបតី នាហ្មឺនមន្ត្រីបណ្ដានគរតូចធំជាច្រើន ព្រមទាំងពុទ្ធបរិស័ទទាំងអស់ នាំគ្នាកគ្រឹកកគ្រេងចូលមកធ្វើសក្ការបូជាដល់ព្រះសរីរៈ ដោយគ្រឿងក្រអូប ផ្កាកម្រង របាំ ចំរៀង ភ្លេងប្រគំជាដើម។ នៅថ្ងៃទី៧ គឺថ្ងៃពុធ ៨រោច ខែពិសាខ ឆ្នាំម្សាញ់ ទើបពួកមល្លក្សត្រ អ្នកក្រុងកុសិនារា និងពុទ្ធបរិស័ទថ្វាយព្រះភ្លើងព្រះសរីរៈព្រះសព នៅមកុដពន្ធនៈចេតិយឬអង្គរៈចេតិយ នៅខាងកើតក្រុងកុសិនគរៈ។

ព្រះពុទ្ធសារីកធាតុ បានរើសដាក់ក្នុងកោដ្ឋមាស រួចនឹងយកទៅដំកល់ទុកក្នុងសណ្ឋាគារដ្ឋាន ហើយនាំគ្នាធ្វើសក្ការៈបូជាអស់៧ថ្ងៃថែមទៀត។

ដោយបារមីនៃនក្ខត្តឫក្សទាំងបីនេះហើយបានជាពុទ្ធសាសនិកជន រស់នៅជុំវិញពិភពលោកយើងនេះ នាំគ្នាប្រារព្ធពិធីនេះឡើង ដើម្បីសំដែងការគោរពប្រតិបត្តិចំពោះគុណបុណ្យបារមី របស់ព្រះពុទ្ធបរមគ្រូ ក្នុងការដឹកនាំសព្វសត្វក្នុងភពត្រៃនេះ ឱ្យរួចផុតពីភាពអវិជ្ជា ហើយទទួលបានសុខដុមរមនា និងយល់ដឹងពីតំលៃនៃជីវិតពិតៗសំរាប់កសាងខ្លួន..***(តទៅទំព័រទី២១)***

# ពិធីពូនភ្នំខ្សាច់ នៅពេលបុណ្យចូលឆ្នាំថ្មី ឆ្នាំខាល ទោស័ក ព.ស ២៥៥៤

នៅពេលបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរ រយៈពេល ៣ថ្ងៃ នៅគ្រប់វត្តអារាមទាំងអស់ ព្រះសង្ឃ និងគណៈកម្មការ អាចារ្យវត្ត តែងតែរៀបចំពិធីពូនភ្នំខ្សាច់ នៅថ្ងៃទី២នៃបុណ្យចូលឆ្នាំ គឺថ្ងៃវ័នបត មានន័យថាការចែកឆ្នាំចាស់និងឆ្នាំថ្មី។ ការពូនភ្នំខ្សាច់នេះ ធ្វើឡើងដើម្បីរំដោះនូវអំពើគ្រោះកាចចង្រៃផ្សេងៗ ក្នុងឆ្នាំចាស់ចេញឱ្យជ្រះស្រឡះពីសន្តានចិត្តនឹងត្រៀមខ្លួនទទួលយកសិរីសួស្តីជោគជ័យបវរមហាប្រសើរក្នុងឆ្នាំថ្មី។

យោងតាមឯកសារខ្លះ បានបង្ហាញថា ការពូនភ្នំខ្សាច់នេះ គឺគេពូនភ្នំធំមួយចំកណ្តាល និងភ្នំតូចៗ៤ នៅសងខាង ហើយធ្វើជារាជវ័តិព័ន្ធជុំវិញ មានទ្វារចេញចូលទាំង៤ទិសដែលហៅថា **វាលុកចេតិយ**។ ភ្នំធំនៅចំកណ្តាលនោះ គឺតំណាងព្រះសក្យមនីចេតិយ ជាទីបញ្ចុះព្រះសារីរិកធាតុរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង រីឯភ្នំតូចៗនៅជុំវិញទាំង៤នោះដែរ គឺជាតំណាងចេតិយបញ្ចុះព្រះអដ្ឋិធាតុរបស់ ព្រះសារីបុត្រ ព្រះមោគ្គល្លាន ព្រះអានន្ទ និងព្រះមហាកស្សប ដែលជាសាវកសំខាន់ៗ សុទ្ធសឹងតែព្រះអរហន្តមានគុណធំមខ្ពស់ក្នុងសម័យព្រះពុទ្ធ។ ម្យ៉ាងទៀតខ្មែរយើងតែងតែមានជំនឿជឿជាក់ថា គ្រាប់ខ្សាច់មួយៗគ្រាប់ដែលចាក់ពូននោះ អាចផ្តល់អានិសង្សដល់អ្នកដែលបានពូន ឱ្យរួចរំដោះនូវបាបគ្រោះ កម្មពៀរវេរាទាំងពួងទៀតផង។

មហាសំការសូត្រ បានពន្យល់អំពីអានិសង្សនៃការពូនភ្នំខ្សាច់នេះថា កាលព្រះសម្ពុទ្ធទ្រង់ធរមាននៅពេលសង្ក្រាន្តថ្មីចូលមកដល់ ព្រះបាទបសេនទិកោសល បានចូលទៅទូលសួរព្រះពុទ្ធថា «មុនពេលព្រះអង្គទ្រង់បរិនិព្វានទៅ បើដល់រដូវសង្ក្រាន្តចូលឆ្នាំថ្មីម្តងៗតើខ្ញុំព្រះករុណាគួរបំពេញបុញ្ញកម្មអ្វីខ្លះ?»

ព្រះពុទ្ធទ្រង់ត្រាស់ថា «បពិត្រមហារាជ! គួរតែព្រះអង្គកសាង **វាលុកចេតិយ** នៅឆ្នេរស្ទឹង ឬ ទន្លេ ហើយនាំយកគ្រឿងសក្ការៈ មានទៀន ធូប គ្រឿងក្រអូប ផ្កាភ្ញីជាដើម មកបូជាចុះ»។



អ្នកស្រី ឈុំ សាមី និងពុទ្ធបរិស័ទធ្វើពិធីពូនភ្នំខ្សាច់ នៅវត្តខេមររង្សី

ពេលនោះ ព្រះបាទបសេនទិកោសល ក៏បានសំរេចព្រះទ័យចំណាយធនធានផ្ទាល់ខ្លួនកសាង **វាលុកចេតិយ** មួយសំរាប់ឧទ្ទិសក្នុងព្រះពុទ្ធសាសនា។

ដោយឡែកវត្តខេមររង្សី ក្រុងសាន់ហូសេ្ស នៅពេលបុណ្យចូលឆ្នាំខ្មែរម្តងៗ ព្រះសង្ឃ គណៈកម្មការវត្ត បានរៀបចំពិធីពូនភ្នំខ្សាច់ ទៅតាមប្រពៃណី ដោយមានការឧបត្ថម្ភពីអ្នកស្រី **ឈុំ សាមី** ម្ចាស់ហាងមាសឡាក់គី។អ្នកស្រីគឺជាពុទ្ធបរិស័ទមួយរូបដែលមានសទ្ធាជ្រះថ្លាក្នុងការចូលរួមចំណែកកសាងវត្តខេមររង្សី និងព្រះពុទ្ធសាសនា មិនដែលនឿយណាយឡើយ ។

ព្រះសម្មាសម្ពុទ្ធព្រះអង្គបានសំដែងអំពីអានិសង្សនៃការពូនភ្នំខ្សាច់ដូច្នេះថា ពុទ្ធបរិស័ទទាំងឡាយណាដែលបានចូលរួមពូនភ្នំខ្សាច់ឬកសាងវាលុកចេតិយនោះ ហើយបានយកចង្ហាន់ទៅប្រគេនព្រះសង្ឃជារបង្សុកូលឧទ្ទិសកុសលជូនញាតិកាទាំង៧សន្តាន និងនាំយកផ្កាភ្ញី គ្រឿងក្រអូប គ្រឿងលាបទៅបូជាព្រះចេតិយដោយសទ្ធាជ្រះថ្លា ពុទ្ធបរិស័ទទាំងនោះនឹងរមែងបានទទួលនូវផលានិសង្សច្រើនសំរាប់ពេលបច្ចុប្បន្ន និង ទៅអនាគត។

សូមបញ្ជាក់ថា នៅថ្ងៃបញ្ចប់បុណ្យចូលឆ្នាំគេធ្វើពិធីបន្សឹកភ្នំខ្សាច់ រួចគេទុកខ្សាច់នោះសំរាប់សាងសង់សមិទ្ធិផលផ្សេងៗ ដើម្បីជាប្រយោជន៍សំរាប់វត្តអារាម និងជាបុណ្យកុសលផងដែរ៕

*ដោយ ស៊ឹម ចន្ទ្រា*

# អបអរសាទរបុណ្យចូលឆ្នាំថ្មី ឆ្នាំខាល ទោស័ក ព.ស ២៥៥៤ វត្តខេមររង្សី

កាលពីថ្ងៃទី១៧-១៨ ខែមេសា ឆ្នាំ២០១០កន្លងទៅហើយនេះ ព្រះសង្ឃ គណៈកម្មការ អាចារ្យវត្ត និង ពុទ្ធបរិស័ទវត្តខេមររង្សី ក្រុងសាន់ហូសេ្ស បានរៀបចំពិធីអបអរសាទរទទួលទេវតាឆ្នាំថ្មីដោយមានការអញ្ជើញចូលរួមពីពុទ្ធបរិស័ទជិតឆ្ងាយយ៉ាងច្រើនកុះករនឹងមានការនិមន្តព្រះសង្ឃបិណ្ឌបាត្រ ដារបង្សុកូល ពូនភ្នំខ្សាច់ ស្រង់ទឹកព្រះរយៈពេលពីរថ្ងៃ ដើម្បីទទួលយកកុសលផលបុណ្យ និងសូមសុខសួស្តីបវរមហាប្រសើរក្នុងការកសាងជីវភាពថ្មី សង្គមថ្មី បំភ្លេចនូវរឿងរ៉ាវអពមង្គលឆ្នាំចាស់ចោល អបអរចំពោះធម្មជាតិថ្មី ការងារថ្មី ព្រមទាំងសំដែងកតញ្ញូតាធម៌ ចំពោះបុព្វការីជនមានមាតាបិតា ជីដូនជីតា គ្រូបាធ្យាយ និងគោរពដល់ដួងវិញ្ញាណក្ខន្ធនៃវីរសមណៈវីរបុរសគ្រប់ជំនាន់ ព្រមទាំងទំនុកបំរុងថែរក្សា ការពារវិស័យព្រះពុទ្ធសាសនា ជាពិសេសបណ្តុះបណ្តាលព្រហ្មវិហារធម៌ សាមគ្គីធម៌ ក្នុងដួងចិត្តខ្មែរយើងឱ្យធំទូលាយក្នុងការកសាងសង្គមជាតិ។




ពុទ្ធបរិស័ទកំពុងដាក់បាត្រព្រះសង្ឃនៅពេលបុណ្យចូលឆ្នាំ



*ពុទ្ធបរិស័ទកំពុងស្តាប់ព្រះសង្ឃចំរេីនព្រះបរិត្ត ពេលបុណ្យចូលឆ្នាំ*




*ក្រុមរបាំអប្សរា ក្រុងសាន់ហូសេ្ស រាំជូនពរឆ្នាំថ្មី*

បន្ទាប់ពីវេរភត្តប្រគេនព្រះសង្ឃរួច ក្រុមរបាំអប្សរា ក្រុងសាន់ហូសេ្ស ដឹកនាំដោយ អ្នកស្រី យឹម កែវប្រធានសមាគមអប្សរានិងអ្នកគ្រូ Doravind Mongkoul បានរាំរបាំជូនពរ,របាំមុនីមេខាឡា, របាំត្រុដិ ជូនដល់ភ្ញៀវកិត្តិយសទស្សនាកំសាន្ត និង មានក្រុមសិស្សសាលាភាសាខ្មែរក្រុងសាន់ហូសេ្ស ដឹកនាំដោយលោកគ្រូកោះ ថុន ចូលរួមសំដែងឈុតខ្លីៗអំពីការថែរក្សាអនាម័យនៅក្នុងពិធីនោះដែរ។

លុះពេលរសៀលព្រះសង្ឃ គណៈកម្មការរៀបចំបុណ្យនិងពុទ្ធបរិស័ទទាំងអស់ ធ្វើវិធីដង្ហែព្រះសិរសាកបិលមហាព្រហ្ម រួចវេរជូនទេវតាឆ្នាំថ្មីទៅតាមទំនៀមទម្លាប់ប្រពៃណីនៃមហាសង្ក្រាន្ត និង មានក្រុមដូរ្យតន្ត្រីប្រគំកំដរជូនរាំកំសាន្ត សប្បាយរីករាយផងដែរ។

គណៈកម្មការវត្តនិងអ្នកចូលរួមជាច្រើនបានជំរាបជូនថា បុណ្យចូលឆ្នាំថ្មី នាឆ្នាំនេះមានភាពសប្បាយរីករាយជាងឆ្នាំមុនៗ ដោយមានពុទ្ធបរិស័ទមកពីទីក្រុងផ្សេងៗយ៉ាងច្រើនដូចជាស្តុកតុន សាន់ហ្វ្រាន់ អូកឡិនជាដើម។

នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំខាល ទោស័ក ព.ស ២៥៥៤នេះ ព្រះសង្ឃ គណៈកម្មការ អាចារ្យវត្តខេមររង្សី សូមថ្លែងអំណរអរគុណ..*(តទៅទំព័រទី២៨)*

(តមកពីទំព័រទី៦) ត្រូវមាន់ចិញ្ចឹមមាន ឈ្មោះថា **កកុសន្ធោ** បុរសដែលត្រូវនាគចិញ្ចឹមមាន ឈ្មោះថា **កោនាគមនោ** បុរសដែលត្រូវអណ្តើកចិញ្ចឹមមាន ឈ្មោះថា **កស្សបោ** បុរសដែលត្រូវគោចិញ្ចឹមមាន ឈ្មោះថា **គោតមោ** បុរសដែលត្រូវខ្លាឬរាជសីហ៍ចិញ្ចឹមមាន ឈ្មោះថា **អរិយមេត្តេយ្យោ**។

ដោយសារមូលហេតុបញ្ជាក់ខាងលើនេះហើយ បានយើងឃើញគេគូររូបសត្វទាំង៥ នៅក្រោមព្រះពុទ្ធគ្រប់ៗអង្គទាំងអស់ តាមជញ្ជាំងព្រះវិហារ សាលាធម្មសភាជាដើម។

ថ្វីត្បិតតែ សាវតារព្រះពុទ្ធទាំង៥ ជាពុទ្ធនិយមដែលជាលក្ខណៈសកលក៏ពិតមែន ប៉ុន្តែវាបានឆ្លុះបញ្ចាំងនូវជំនឿបែបបទខ្មែរសុទ្ធសាធ ស្តីអំពីការចាប់ជាតិឡើងវិញនៃព្រលឹងក្នុងវាលវដ្តសង្សារក្រោយពីការកើត ហើយស្លាប់ទៅវិញរបស់មនុស្សជាតិ។

ទោះបី ពេលវេលាកន្លងផុតទៅអស់ជាច្រើនសតវត្សរ៍ហើយក្តី ក៏សាវតារព្រះពុទ្ធទាំង៥ព្រះអង្គរបស់យើងនៅតែរក្សាបាននូវប្រជាប្រិយភាពនិងទទួលការគោរពប្រតិបត្តិពីពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋានទាំងអស់។ ព្រះសង្ឃ និងពុទ្ធសាសនិកជននៅតាមវត្តអារាមតែងតែរំឭកនឹកដល់ព្រះគុណនៃព្រះពុទ្ធទាំង៥នោះគ្រប់ពេលវេលា។

សូមបញ្ជាក់ថា ព្រះពុទ្ធទាំង៤អង្គខាងដើម បានត្រាស់ដឹងជាព្រះពុទ្ធរួចហើយ។ សព្វថ្ងៃនេះពុទ្ធបរិស័ទនៅលើសលកលោកកំពុងតែគោរពប្រតិបត្តិ និងមានជំនឿយ៉ាងខ្លាំងទៅលើសាសនាព្រះពុទ្ធសមណគោត្តមបរមគ្រូនៃយើងដោយព្រះពុទ្ធសាសនា ជាសាសនាមួយបញ្ជាក់ពីហេតុផលច្បាស់លាស់ ព្រមទាំងពន្យល់ណែនាំដល់មនុស្សទូទៅឱ្យបានយល់ច្បាស់អំពើល្អ អាក្រក់និងឱ្យប្រកាន់ខ្ជាប់នូវគុណធម៌ សីលធម៌ ព្រហ្មវិហារធម៌ សច្ចធម៌ ក្នុងការដឹកនាំសត្វលោកឆ្ពោះទៅរកផ្លូវសុខសន្តិភាព ទាំងផ្លូវកាយ ផ្លូវចិត្ត ប្រកបដោយឧត្តមគតិខ្ពស់ សំរាប់ជាតិ សាសនា និងជីវិតប្រចាំថ្ងៃ ក្នុងពេលបច្ចុប្បន្ននិងទៅអនាគត។ ចំណែកព្រះពុទ្ធទី៥គឺ **អរិយមេត្តេយ្យោ** ពុំទាន់បានត្រាស់ទេ កំពុងកសាងបារមី ដើម្បីឱ្យបានត្រាស់ដឹងជាព្រះពុទ្ធ បន្ទាប់ពីសាសនាសមណគោត្តមនេះទៅ៕

## ***ដំណឹងសិក្សា***
## ***ភាសាខ្មែរ និងរបាំប្រពៃណីបុរាណខ្មែរ***

*ពុទ្ធិកសមាគមខ្មែរក្រោម* ***វត្តខេមររង្សី*** *និងក្រុមរបាំអប្សរា នៅទីក្រុងសាន់ហូសេ្ស មានកិត្តិយសសូមជំរាបជូនដំណឹងដល់បងប្អូនជនរួមជាតិខ្មែរ គ្រប់មជ្ឈដ្ឋាន ឲ្យបានជ្រាប សូមទានជ្រាប ៖*

*** *កម្មវិធីសិក្សាភាសាខ្មែរ ជារៀងរាល់ថ្ងៃសុក្រ និងសៅរ៍ ចាប់ពីម៉ោង* **4:00PM - 5:00PM**

*** *កម្មវិធីបង្ហាត់របាំប្រពៃណីខ្មែរ ជារៀងរាល់ថ្ងៃសុក្រ ចាប់ពីម៉ោង* **6:00PM - 8:00PM**

*អាស្រ័យហេតុនេះ សូមអញ្ជើញអាណាព្យាបាល និងសិស្សានុសិស្ស គ្រប់ស្រទាប់វណ្ណៈ ដែលមានទឹកចិត្តស្រឡាញ់ និងលើកស្ទួយវិស័យវប្បធម៌ខ្មែរ មេត្តារួសរាន់នាំបុត្តធីតារបស់លោក អ្នក មកសិក្សាភាសាខ្មែរ និងរបាំប្រពៃណីជាតិ ដោយសោមនស្សរីករាយ។*

*** ***ទីកន្លែង:*** *វត្តខេមររង្សី* **1594 Cunningham Ave, San Jose. CA 95122 Tel: (408) 923-2166**

# បុណ្យគំរប់ខួប១០០ថ្ងៃ និងបុណ្យឈាបនកិច្ច នៅវត្តខេមររង្សី ក្រុងសាន់ហ្វូស្សេ



ពុទ្ធបរិស័ទចូលរួមក្នុងពិធីបុណ្យគំរប់ខួប១០០ថ្ងៃរបស់អ្នកស្រីជួប ហុង

កាលពីថ្ងៃទី៤ មេសា ឆ្នាំ២០១០កន្លងទៅថ្មីៗនេះ លោកយាយជួប មុក និងលោក សុខ ម៉ាឡៃ ព្រមទាំងញាតិមិត្តជិតឆ្ងាយ បានរៀបចំពិធីបុណ្យខួបគំរប់១០០ថ្ងៃ ជូនចំពោះដួងវិញ្ញាណក្ខន្ធ អ្នកស្រី ជួប ហុងនៅវត្តខេមររង្សី ទីក្រុងសាន់ហ្វូស្សេ។

កម្មវិធីបុណ្យប្រព្រឹត្តទៅតាមប្រពៃណី ព្រះពុទ្ធសាសនា ដោយមានកិច្ចនមស្សការ សមាទានសីល រាប់បាត្រ និងវេរភត្តប្រគេនព្រះសង្ឃ ដារបង្សុកូល ដើម្បីឧទ្ទិសមហាកុសលជូនចំពោះវិញ្ញាណក្ខន្ធ អ្នកស្រី ជួប ហុង ដែលបានចែកឋានទៅកាន់លោកខាងមុខហើយនោះ។ សូមរំឮក ផងថា អ្នកស្រី ជួប ហុង គឺជាពុទ្ធបរិស័ទមួយរូប ដែលមានសទ្ធាជ្រះថ្លារួមចំណែកក្នុងការជួយឧបត្ថម្ភគាំទ្រ និងកសាងវិស័យព្រះពុទ្ធសាសនា នៅវត្តខេមររង្សី ជាពិសេសអ្នកស្រីបានលះបង់ធនធានជាច្រើន សំរាប់ទ្រទ្រង់វប្បធម៌ ប្រពៃណី អក្សរសាស្ត្រខ្មែរផងដែរ៕



ពុទ្ធបរិស័ទវេរភត្តប្រគេនព្រះសង្ឃ ក្នុងពិធីបុណ្យឈាបនកិច្ចលោកយាយនាង គង់ នៅវត្តខេមររង្សី ក្រុងសាន់ហ្វូស្សេ

## បុណ្យឈាបនកិច្ច

សង្ខាររបស់មនុស្សគ្រប់ៗរូប គេចមិនផុតពីសេចក្ដីស្លាប់ឡើយ គ្រាន់តែទៅតាមកម្មផលដែលខ្លួនបានកសាង អ្នកខ្លះស្លាប់ពីក្មេង អ្នកខ្លះស្លាប់ពាក់កណ្ដាលវ័យ អ្នកខ្លះទៀតស្លាប់នៅពេលចាស់ជរា។

តែគួរឱ្យសង្វេគ និង សោកស្ដាយជាទីបំផុតរកអ្វីមកប្រៀបស្មើគ្មាននោះ គឺឧបាសិកា នាង គង់ ដែលជាពុទ្ធបរិស័ទមួយរូប បានលះបង់ធនធានជាច្រើន ដើម្បីរួមចំណែកកសាងសមិទ្ធិនានាក្នុងវិស័យព្រះពុទ្ធសាសនា និងសង្គមជាតិ តែពេលនេះលោកយាយបានទទួលមរណៈភាពកាលពីថ្ងៃអង្គារ ទី២០ មេសា ឆ្នាំ២០១០ ក្នុងជន្មាយុ៩២ឆ្នាំ ដោយជរាពាធរួចទៅហើយ។

ដើម្បីសំដែងកតញ្ញូកតវេទិតាធម៌ចំពោះលោកយាយ កូនចៅ ញាតិមិត្ត បានរៀបចំពិធីបុណ្យទក្ខិណានុប្បទាន កាលពីថ្ងៃទី២៤ មេសា ឆ្នាំ២០១០ នៅវត្តខេមររង្សី ទៅតាមព្រះពុទ្ធសាសនា ក្នុងន័យឧទ្ទិសមហាកុសលជូនដល់ដួងវិញ្ញាណក្ខន្ធលោកយាយ ដោយមានពិធីធ្វើកិច្ចនមស្សការ សមាទានសីល រាប់បាត្រ វេរភត្តប្រគេនព្រះសង្ឃជាដើម។

នេះហើយសបញ្ជាក់ឱ្យឃើញថា ប្រពៃណី ទំនៀមទម្លាប់របស់ខ្មែរយើងតាំងពីបុរាណកាលមក តែងតែគោរពប្រតិបត្តិព្រះពុទ្ធសាសនា ជឿជាក់ទៅលើកម្មផល ក្នុងការបំពេញទាន កុសលផលបុណ្យ ដើម្បីឧទ្ទិសជូនអ្នកមានគុណ និងកសាងនូវអំពើល្អសំរាប់ខ្លួនឯងទាំងពេលបច្ចុប្បន្ន និងទៅអនាគត៕

# មនុស្សមានប្រយោជន៍ដល់សង្គម

កើតមកជាមនុស្សគឺជាការមួយកម្រខ្លាំងណាស់ តែបើបានកើតមកហើយត្រូវខិតខំសាងខ្លួនឱ្យក្លាយទៅជាបុគ្គលល្អប្រពៃសំរាប់អូសទាញខ្សែជីវិតរបស់ខ្លួននិងសង្គមជាតិឆ្ពោះទៅរកភាពរីកចំរើនស្របតាមទ្រឹស្តីព្រះពុទ្ធសាសនានិងច្បាប់នៃប្រទេសដែលខ្លួនរស់នៅ។

ព្រះពុទ្ធសាសនា ជាសាសនាមួយដែលមានពន្លឺច្បាស់លាស់ក្នុងការចង្អុលបង្ហាញផ្លូវសព្វសត្វទាំងអស់ទៅកាន់ទីសុខក្សេមក្សាន្ត និងមានស្មារតីរឹងប៉ឹង ចេះតស៊ូក្នុងឆាកជីវិត ដូច្នេះព្រះពុទ្ធបានអប់រំ ទូន្មានពន្យល់ណែនាំដល់សាវករបស់ព្រះអង្គនិងពុទ្ធបរិស័ទទាំងអស់ថា បុគ្គលគ្រប់រូប គ្រប់វណ្ណៈត្រូវចេះធ្វើខ្លួនឱ្យមានប្រយោជន៍ដល់សង្គមនិងជួយផ្តល់សេចក្តីសុខដល់អ្នកដទៃត្រូវប្រព្រឹត្តធម៌ទាំង៤ប្រការ ជាសភាវៈប្រចាំចិត្តគឺៈ

**១/មេត្តា** ត្រូវតែមានបំណងប្រាថ្នាឱ្យមនុស្សសត្វទាំងអស់បាននូវគុណប្រយោជន៍ និងសេចក្តីថ្លៃថ្នូរដោយបានឃើញចំពោះតម្រូវការនៃមនុស្សគ្រប់ៗរូប ដែលត្រូវការភាពសុខសាន្ត។

**២/ករុណា** គឺគិតពីបំណងប្រាថ្នាត្រូវជួយដល់អ្នកក្រីក្រ អ្នកទន់ខ្សោយ និងអ្នកដែលមានវិបត្តិផ្សេងៗឱ្យបានរួចផុតពីទុក្ខ ដោយយើងកំណត់ដឹងថា សត្វទាំងឡាយសុទ្ធតែភ័យខ្លាចចំពោះសេចក្តីអន្តរាយ ព្រមទាំងមិនប្រាថ្នានូវទុក្ខលំបាកគ្រប់ៗគ្នា។

**៣/មុទិតា** ធ្វើចិត្ត និងអារម្មណ៍ ឱ្យទន់ភ្លន់នឹងននៅពេលអ្នកដទៃជួបប្រទះរឿងរ៉ាវមិនគួរគប្បីដែលបានកើតឡើង និង មិនត្រូវមានចិត្តច្រណែនឈ្នានីសជាមួយអ្នកនៅក្បែរខ្លួន ថែមទាំងមានចិត្តសប្បាយរីករាយដោយសទ្ធាជ្រះថ្លាជឿជាក់ចំពោះផលវិបាករបស់កម្ម។

**៤/ឧបេក្ខា** មានចិត្តជាកណ្តាល មិនលំអៀង ប្រកាន់យកភាពយុត្តិធម៌ និងតម្លាភាព សម្លឹងមើលទៅមនុស្សគ្រប់ៗរូបតាមសេចក្តីពិតនៃជីវិត។ ភាពពិតនៃជីវិតសត្វលោកទាំងអស់រមែងប្រព្រឹត្តទៅតាមកម្មផលប្រៀបដូចនាយសារថី កាលសេះរត់ត្រូវផ្លូវរៀបរយល្អហើយ ក៏អង្គុយស្ងៀមសម្លឹងមើលទៅមុខស្មើៗទៅតាមដំណើររៀបរយរបស់គេដូច្នោះឯង។

កាលបើមានព្រហ្មវិហារធម៌ខាងក្នុងខ្លួន ជាភូមិឋានដូច្នេះហើយ យើងគប្បីសំដែងចេញមកខាងក្រៅទៅតាមគោលធម៌សង្គ្រោះឬជាធម៌ជួយទំនុកបំរុងជាគ្រឿងដែលធ្វើមនុស្សគួជាទីចាប់ចិត្តមាន៤ប្រការគឺៈ

**១/ទាន** ការឱ្យនូវវត្ថុដែលគួរឱ្យ គឺបានដល់ការផ្តល់ជាដើមទុននិងជួយសង្គ្រោះអ្នកទ័លក្រជាពិសេសផ្តល់នូវចំណេះដឹងផ្សេងៗព្រមទាំងបង្រៀនពីគុណធម៌ សីលធម៌ ចរិយាធម៌ ដើម្បីកុំឱ្យប្រកបការងារទុច្ចរិតនៅក្នុងសង្គម។

**២/បិយវាចា** ពោលនូវពាក្យពីរោះ ដល់អ្នកស្តាប់ត្រូវចេះប្រើសម្តីដូចផ្កាឬដូចទឹកឃ្មុំ ប្រាប់នូវប្រយោជន៍តាមហេតុផលច្បាស់លាស់ និយាយឱ្យកំលាំងចិត្តក្នុងផ្លូវដែលល្អជាដើម។

**៣/អត្ថចរិយា** ធ្វើនូវប្រយោជន៍ដល់អ្នកដទៃ គឺជាការជួយដោយកម្លាំងកាយ ខ្វល់ខ្វាយអើពើក្នុងកិច្ចការ ផ្សេងៗបំពេញភារកិច្ចជាសាធារណប្រយោជន៍ត្រូវមាន ទស្សនៈទូលំទូលាយកុំកេងប្រវ័ញ្ចទ្រព្យសម្បត្តិគេគឺលះបង់ខ្ពស់ ដើម្បីព្រះពុទ្ធសាសនានិងសង្គមជាតិ។

**៤/សមានត្តតា** រៀបចំខ្លួននិងឥរិយាបថឱ្យល្អក្នុងការទំនាក់ទំនងជាមួយសង្គម មិនត្រូវមានចិត្តក្បត់នឹងមិត្តភក្តិបដិបត្តិស្មោះត្រង់ជាមួយមនុស្សទាំងឡាយមិនប្រព្រឹត្តបោកប្រាស់ទៅលើអ្នកទន់ខ្សោយ និង អ្នករួមសុខរួមទុក្ខ រួមដឹងរួមដោះស្រាយដើម្បីប្រយោជន៍រួម។

សរុបមកព្រហ្មវិហារធម៌ និងសង្គហវត្ថុទាំង ៤ នេះ មានតួនាទីសំខាន់ណាស់ ក្នុងការវិនិច្ឆ័យទៅលើសត្វលោក ហាក់បីដូចជាជញ្ជីង..... ***(តទៅទំព័រទី១៩)***

# ល្បែងប្រជាប្រិយខ្មែរប្រឈមនឹងការបាត់បង់

គេកត់សម្គាល់ឃើញថា ល្បែងប្រជាប្រិយខ្មែរជាច្រើនដូចជា បោះអង្គុញ់ ចោលឈូង លាក់កន្សែងជាដើម ហាក់ដូចជាមានការបាត់បង់សាបរលាបបន្តិចម្តងៗទៅហើយ។

នាពេលរដូវបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរជិតចូលមកដល់ម្តងៗ គេឃើញនៅតាមបណ្តាស្ថានីយទូរទស្សន៍ វិទ្យុ បានផ្សព្វផ្សាយតាមរយៈពិធីករ ពិធីការិនីនិងមានការបង្ហាញពីគំរូរបៀបលេងល្បែងប្រជាប្រិយខ្មែរដែលក្នុងនោះមានល្បែងស្តេចចង់ បោះឈូង លាក់កន្សែង បោះអង្គុញ់ ចាប់កូនខ្លែង ទាញព្រ័ត្រ និងរាំវង់ប្រពៃណីខ្មែរជាដើម ។ ក៏ប៉ុន្តែនៅក្នុងរដូវបុណ្យចូលឆ្នាំថ្មី ក្នុងឆ្នាំ២០១០នេះ ប្រជាពលរដ្ឋ និងចាស់ព្រឹទ្ធាចារ្យមួយចំនួន បានលើកឡើងថា វាស្ទើរតែមានការបាត់បង់ និងសាបរលាបបន្តិចម្តងទៅហើយ ដោយសារតែម្នាក់ពុំបានយកចិត្តទុកដាក់ថែរក្សា។

ស្ត្រីវ័យ ៨៥ឆ្នាំម្នាក់ ឈ្មោះ អ៊ុំ រឹង មានស្រុកកំណើតនៅខេត្តបាត់ដំបងបានឲ្យដឹងយ៉ាងដូច្នេះ៖ *«មានឃើញតែក្នុង វ៉ាត់ឃូ លេងគគ្រឹកគគ្រេង គេលេងឲ្យយើងឃើញជាគំរូ មែនទែនមិនទាន់ឃើញលេងទេ។ លេងពីរបីថ្ងៃមុនលេងតែមួយភ្លែតទេ»*។

ស្ត្រីឈ្មោះ មា សុខុម មានលំនៅឋាននៅខេត្តព្រៃវែងបានថ្លែងថានៅឆ្នាំនេះគាត់មិនសូវជាបានឃើញមនុស្សម្នា ជាពិសេសយុវវ័យនៅក្នុងភូមិលេងល្បែងប្រជាប្រិយដូចឆ្នាំមុនៗទេ ៖ *«អ្នកលេងតិចជាង ព្រោះអីខ្លះគេទៅរាំបាសខាងនេះ គេអត់សូវលេងទេ លាក់កន្សែងទេ បោះតែអង្គុញ់លេងម្តងៗ តែលេងតិច»*។

ចំណែកឯស្ត្រីវ័យ៤០ឆ្នាំ ម្នាក់ទៀតឈ្មោះ ហេង ប៊ុនណាតរស់នៅភូមិដើមត្នោតសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ បានឲ្យដឹងដែរថា នៅភូមិរបស់គាត់បានចាប់ផ្តើមលេងល្បែងប្រជាប្រិយខ្លះៗហើយ ដោយសារតែប្រជាពលរដ្ឋរវល់ នៅក្នុងការប្រកបមុខរបររកទទួលទាន ហើយម្យ៉ាងទៀតពុំមានទីធ្លាលេងឲ្យបានទូលាយ ។អ្នកស្រី ជុំ សំបិត ប្រធានក្រុមទី៧ ភូមិបឹងសាឡាង សង្កាត់ឫស្សីកែវបានឲ្យដឹងស្រដៀងគ្នានេះដែរថាកាលពីឆ្នាំកន្លងទៅនៅក្នុងភូមិឋានរបស់គាត់ ទាំងក្មេងចាស់ប្រុសស្រីគេនិយមលេងល្បែងប្រជាប្រិយនិងរាំវង់ប្រពៃណីខ្លាំងណាស់។ ការលេងបែបនេះ នៅក្នុងភូមិរបស់គាត់ បានលេងនៅមុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរយ៉ាងហោចណាស់២ទៅ ៣ខែដែរ ហើយនៅពេលជិតដល់ពិធីបុណ្យចូលឆ្នាំ២ឬ៣ថ្ងៃ ទើបពួកគេធ្វើដំណើរទៅស្រុកកំណើត ក៏ប៉ុន្តែនៅឆ្នាំនេះ មិនដូចមុនទៀតទេ។



ប្រជាពលរដ្ឋខ្មែរលេងល្បែងចោលឈូង នៅពេលបុណ្យចូលឆ្នាំ

គណៈកម្មការវត្តទួលសង្កែ លោក ឡុង ហួន អាយុ ៧៦ឆ្នាំ មានប្រសាសន៍ថា ក្មេងៗ និងយុវវ័យបច្ចុប្បន្ននេះ ពុំសូវចាប់អារម្មណ៍លេងល្បែងប្រជាប្រិយទេ ដោយសារតែល្បែងស៊ីសងពាលាអាវាសែ សេពគ្រឿងញៀននិងគ្រឿងស្រវឹងមិនដូចចាស់ពីជំនាន់ដើមលេងល្បែងប្រជាប្រិយគោរពសិទ្ធិគ្នាណាស់។

ស្ត្រីវ័យឌឹក ធុចអាយុ៧២ឆ្នាំមានស្រុកកំណើតនៅខេត្តព្រៃវែងបានថ្លែងថាយុវវ័យសម័យឥឡូវមិនសូវមានចំណូលចិត្តលេងល្បែងប្រជាប្រិយទេគាត់យល់ថា ម្នាក់ៗ រវល់តែប្រកបកិច្ចការរកទទួលទានចិញ្ចឹមជីវិតពុំបានគិតគូររឿងលេងនោះទេដោយសារតែបច្ចុប្បន្នពិបាករកចំណូលណាស់និងមានហេតុផលជាច្រើនទៀត ។ទោះបីជាមានការលើកឡើងថា... ***(តទៅទំព័រទី១៥)***

# ពិធីអុជទៀនរំលឹកដួងវិញ្ញាណក្ខ័ន្ធអ្នកស្លាប់ក្នុងសម័យសង្គ្រាម នៅសាលាស្រុក San Jose

កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០កន្លងទៅ ហើយថ្មីៗនេះ នៅសាលាស្រុក San Jose មានរៀបចំពិធីអុជទៀន ដើម្បីរំលឹកនិងគោរពវិញ្ញាណក្ខន្ធ អ្នកដែលបានបូជាជីវិតនិងស្លាប់ក្នុងភ្លើងសង្គ្រាមសម័យហ៊ីត្លែរ បានសម្លាប់ជនជាតិជ្វីបអស់ជាច្រើន។

ពិធីនេះរៀបចំឡើងដោយពួកជនជាតិជ្វីប និងជាតិសាសន៍ដទៃទៀត នឹងមានការជួយឧបត្ថម្ភគាំទ្រពីសំណាក់សាលាស្រុកSanJoseក្នុងអត្ថន័យរំលឹកដឹង



ពិធីអុជទៀនគោរពវិញ្ញាណក្ខន្ធអ្នកស្លាប់ ក្នុងសម័យសង្គ្រាមហ៊ីត្លែរ



អ្នកស្រី វិនីតា គីលិន អុជទៀនរំលឹកដល់អ្នកស្លាប់ដោយសារសង្គ្រាម

គុណចំពោះអ្នកតស៊ូទាមទារនូវសិទ្ធិសេរីភាព និង ពួកឈ្លើយសង្គ្រាមក្នុងរបបនោះ គឺស្លាប់យ៉ាងវេទនាជាទីបំផុតអស់រាប់សែននាក់។ នេះជាសោកនាដកម្មមួយមិនអាចបំភ្លេចបាន ធ្វើឱ្យដក់ជាប់ក្នុងអារម្មណ៍របស់ពួកគេគ្រប់ៗរូបហើយចងចាំនៅក្នុងខួរក្បាលអស់មួយជីវិត នៅការព្រាត់ប្រាស់សាច់ញាតិ បងប្អូន កូនចៅជាដើម។

នៅក្នុងពិធីនោះដែរ ដោយមានការអញ្ជើញចូលពីអ្នកស្រី Channary Bill ប្រធានសមាគមស្ត្រីខ្មែរក្រុងសាន់ហ្វូស្សេ។ អ្នកស្រីបានអញ្ជើញឡើងអុជទៀននិងមានប្រសាសន៍ជំរាបជូនអង្គពិធីទាំងមូល ពីភាពទុក្ខលំបាករបស់ប្រជាពលរដ្ឋខ្មែរ នៅក្នុងរបបសម័យខ្មែរក្រហមនោះផងដែរ។

អ្នកចូលរួមទាំងអស់ បានសំដែងភាពក្តុកក្តួលរំជួលចិត្តនិងសោកសង្រេងយ៉ាងខ្លាំង ដែលពួកគេបានបាត់បង់សមាជិកគ្រួសារ ជាពិសេសត្រូវបានគេចាប់ធ្វើជាឈ្លើយសង្គ្រាម ដាក់គុក ធ្វើទារុណកម្ម កាប់សម្លាប់យ៉ាងព្រៃផ្សៃ។ បើយើងសំឡឹងមើលស្រមោលពីអតីតកាលរបស់ប្រទេសកម្ពុជាវិញនោះ មិនខុសគ្នាប៉ុន្មានពីសម័យហ៊ីត្លែរទេគឺពួកខ្មែរក្រហមបានសម្លាប់និងធ្វើទុក្ខម្នេញដល់ប្រជាពលរដ្ឋខ្មែរស្លាប់អស់រាប់លាននាក់ និងបានបន្សល់ទុកនៅកុមារកំព្រា ស្ត្រីមេម៉ាយ រហូតដល់សព្វថ្ងៃនេះ។

អ្នកស្រី វិនីតា គីលិន តំណាងវត្តខេមររង្សី ដែលបានចូលរួមក្នុងកម្មវិធីនោះ មានប្រសាសន៍ថា អ្នកស្រីតែងតែនឹកឃើញពីសេចក្តីទុក្ខវេទនារបស់ខ្មែរយើងក្នុងសម័យសង្គ្រាមប្រល័យពូជសាសន៍នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាពិសេសបងប្អូនខ្មែរក្រោម ដែលរស់នៅក្រោមការ ត្រួតត្រានៃរដ្ឋអំណាចក្រុងហាណូយ បានទទួលរងនូវការរំលោភសិទ្ធិសេរីភាពមកលើព្រះសង្ឃនិងប្រជាពល រដ្ឋខ្មែរមិនឈប់ឈរឡើយ។

សូមបញ្ជាក់ថា ការរំលឹកនិងការគោរពវិញ្ញាណក្ខន្ធនេះ គេប្រារព្ធធ្វើនៅខែមេសាជារៀងរាល់ឆ្នាំ ក្រុមអ្នករៀបចំកម្មវិធី បានអំពាវនាវគ្រប់ជាតិសាសន៍ទាំងអស់ ដែលធ្លាប់រស់នៅ និងឆ្លងកាត់ភ្លើងសង្គ្រាម ចូលរួមឱ្យបានច្រើនដើម្បីសំដែងការដឹងគុណនិងរំលែកទុក្ខចំពោះអ្នកស្លាប់ក្នុងរបបនោះ៕ ដោយ ថាច់ តារា

*(តមកពីទំព័រទី១៣)* យ៉ាងនេះក្តី យុវវ័យមួយចំនួនបានអះអាង មូលហេតុដែលនាំឱ្យពួកគេមិនបានលេងល្បែងប្រជាប្រិយនោះ គឺមកពីមជ្ឈដ្ឋានមិនបានអំណោយផល។នៅក្នុងភូមិឋានពុំមានទីធ្លាឱ្យពួកគេបានលេងនោះទេ ចំណែកនារីៗមួយចំនួនក៏មិនសូវសហការលេងដែរ ដោយសារតែមានការប្រកាន់ច្រើន។រីឯចាស់នៅក្នុងភូមិ ក៏មិនបង្កបរិយាកាសឱ្យពួកគេបានលែងដែរ។

ឆ្លើយតបទៅនឹងបញ្ហានេះលោក ជុច ភឿនរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានប្រសាសន៍ថា លោកទទួលស្គាល់ចំពោះការថមថយនៃការលេងល្បែងប្រពៃណីខ្មែរ ដែលវាអាចនឹងប្រឈមទៅនឹងការបាត់បង់ម្តងបន្តិច ដោយសារការមិនយកចិត្តទុកដាក់ខ្វះការផ្តួចផ្តើមគំនិតបំផុស និងគាំទ្រឲ្យលេងល្បែងប្រជាប្រិយខ្មែរនេះ។ប្រជាពលរដ្ឋ ចាស់ព្រឹទ្ធាចារ្យ និងមន្ត្រីក្រសួងវប្បធម៌មួយចំនួន បានលើកឡើងថា ដើម្បីចៀសវាងនូវការបាត់បង់ល្បែងប្រពៃណីខ្មែរនេះ មានតែយើងទាំងអស់គ្នា រួមគ្នាថែរក្សានិងដាស់តឿន ក្រើនរំឭកយុវវ័យជំនាន់ក្រោយឱ្យលេងនៅពេលមានពិធីបុណ្យទានម្តងៗ ពិសេសនៅរដូវបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។

ល្បែងទាំងនោះពុំមានចារឹកជាក្បួនតម្រាទេ គេលេងតាមចំណាំរៀងៗខ្លួនតៗគ្នាទៅតាមទម្លាប់ស្រុកទេសតែប៉ុណ្ណោះ៕

*ប្រភព RFA*

---

*(តមកពីទំព័រទី៤)* រួចដាក់ក្នុងទ្រុងឡានឲ្យអាជ្ញាធរយួនទៅដាក់គុកយួននៅកម្ពុជាក្រោម។ នេះសបញ្ជាក់ឲ្យឃើញថាប្រទេសកម្ពុជាកំពុងតែស្ថិតក្រោមរណបនយោបាយយួនកុម្មុយនិស្តដែលមិនអាចប្រកែកដោះសារបានឡើយ ។

ជនជាតិដើមខ្មែរក្រោមរាប់លាននាក់កំពុងរស់នៅកម្ពុជាក្រោមដែលជាទឹកដីរបស់ដូនតាពួកគេប៉ុន្តែត្រូវបានពួកអន្តោប្រវេសន៍យួនល្មោភសង្គ្រាមឈ្លានពានឃុបឃិតជាមួយបារាំង ដាក់នឹមអាណានិគមធ្វើទុក្ខបុកម្នេញទាំងយប់ទាំងថ្ងៃ ដោយអាងអំណាចប្រើច្បាប់ព្រៃ ធ្វើបាបព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមយ៉ាងគឃ្លើន ។

វាសនាប្រជាពលរដ្ឋខ្មែរក្រោម រស់ទាំងត្រដរក្នុងក្រញ៉ាំបីសាចយួនដោយគ្មានសេចក្តីសង្ឃឹមទៅលើអ្វីក្រៅពីទឹកចិត្តនិងស្មារតីតស៊ូស្នេហាជាតិប៉ុណ្ណោះ។ មួយទៀតសោតនោះ សង្ឃឹមទៅលើបងប្អូនរួមជាតិខ្មែរនៅប្រទេសកម្ពុជាដែលជាប្រទេសរួមលោហិតជាមួយគ្នានោះ ប៉ុន្តែសេចក្តីសង្ឃឹមនោះបានប្រែក្លាយទៅជាអស់សង្ឃឹមទៅវិញដោយរដ្ឋាភិបាលខ្មែរសព្វថ្ងៃស្ថិតក្រោមបញ្ជានយោបាយយួនក្រុងហាណូយទៀតដូច្នេះប្រជាពលរដ្ឋខ្មែរក្រោមមានតែចុះទឹកក្រពើឡើងលើខ្លាប៉ុណ្ណោះ។

ដោយទឹកចិត្តខ្មែរក្រោមស្រឡាញ់សម្បត្តិ ធម្មជាតិ និងមានឧត្តមគតិស្នេហាជាតិគ្រប់ជំនាន់នោះ ទាំងព្រះសង្ឃ គ្រហស្ថ និស្សិត បញ្ញវ័ន្ត តែងតែការពារនូវអត្តសញ្ញាណជាតិរបស់ខ្លួនមិនឲ្យសាបសូន្យ ហើយជាញឹកញាប់ក្រោកឡើងតស៊ូប្រឆាំងដាច់ខាតជាមួយនឹងបក្សកុម្មុយនិស្តយួន ដែលរំលោភសិទ្ធិជនជាតិខ្មែរក្រោម ។ ក្នុងករណីចលនាតស៊ូ របស់បងប្អូនខ្មែរក្រោម ទាំងនៅលើមាតុភូមិកំណើត និងជុំវិញពិភពលោកនោះ ក្នុងគោលបំណងតែមួយគត់ គឺទាមទារសិទ្ធិសេរីភាព និងសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។

បច្ចុប្បន្ននេះ សហព័ន្ធខ្មែរកម្ពុជាក្រោមបានទទួលការគាំទ្រពីសំណាក់បងប្អូនខ្មែរ និងបរទេសយ៉ាងច្រើនព្រមទាំងជាគណៈកម្មការកណ្តាល នៃអង្គការយូអិនភីអូ (UNPO) ដែលជា**អង្គការ**មួយ **តំណាងឲ្យប្រជាជាតិ និងប្រជាជនដែលគ្មានតំណាង** របស់ខ្លួននៅក្នុងអង្គការសហប្រជាជាតិ ។

ដូច្នេះ វាសនាខ្មែរក្រោមមានសេចក្តីសង្ឃឹមយ៉ាងមុតមាំចំពោះទឹកចិត្តស្នេហាជាតិនិងចលនាអហិង្សារបស់សហព័ន្ធខ្មែរកម្ពុជាក្រោមដែលបានទម្លុះទម្លាយនូវអំពើព្រៃផ្សៃអំពើសោកនាដកម្មអំពើអយុត្តិធម៌ ***(តទៅទំព័រទី២៩)***

# លោកស្រី មួរ សុខ ហួរ ជួបសំណេះសំណាលជាមួយបងប្អូនខ្មែរ នៅវត្តខេមររង្សី ក្រុង San Jose

នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១០ កន្លងទៅហើយនេះ លោកជំទាវមួរ សុខ ហួរអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពតនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញមកសួរសុខទុក្ខ និងធ្វើសេចក្តីរាយការណ៍ ស្តីពីការទុក្ខលំបាក របស់ស្ត្រីនិងប្រជាពលរដ្ឋខ្មែរនៅគ្រប់ខេត្តក្រុងទូទាំងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជូនដល់បងប្អូនខ្មែរយើងរស់នៅរដ្ឋកាលីហ្វ័កនីញ៉ា ភាគខាងជើង។

នៅក្នុងកិច្ចជំនួបនោះដែរ ក៏មានការជួយសំរួល និងផ្តល់ទីកន្លែងពីសំណាក់ គណៈកម្មការ វត្តខេមររង្សី ដោយមានការនិមន្ត និងអញ្ជើញរួមពីព្រះសង្ឃ គណៈកម្មការវត្តសមាជិក-កា នៃគណបក្សសមរង្សី ព្រមទាំងពុទ្ធបរិស័ទជាច្រើនរូបផងដែរ។



*បងប្អូនខ្មែរនៅ Northern California ជួបសំណេះសំណាលជាមួយនឹងអ្នកតំណាងរាស្ត្រ មួរ សុខ ហួរ នៅវត្តខេមររង្សី ក្រុងសាន់ហូសេ្ស*

មុននឹងចាប់ផ្តើមកម្មវិធី តំណាងឲ្យគណបក្សសមរង្សីប្រចាំក្រុងសាន់ហូសេ្ស បានឡើងឧទ្ទេសនាមសមាសភាពដែលបានអញ្ជើញចូលរួមរួចមក។ អ្នកស្រីតំណាងរាស្ត្រធ្វើសេចក្តីរាយការណ៍ ស្តីអំពីស្ថានភាពនយោបាយនៅប្រទេសកម្ពុជាបច្ចុប្បន្ន ដែលទាក់ទងនឹងសិទ្ធិស្ត្រី សិទ្ធិកុមារ និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ អ្នកស្រីបានបញ្ជាក់បន្ថែមថា ក្នុងរយៈពេល១៥ឆ្នាំកន្លងមកនេះ គណបក្សសមរង្សីនឹងខិតខំប្រឹងប្រែងធ្វើយ៉ាងណាឱ្យមានសមភាពក្នុងសង្គម ប្រកបដោយលទ្ធិប្រជាធិបតេយ្យនិងឈរលើមូលដ្ឋានគ្រឹះដ៏រឹងមាំ គឺការ



*លោកស្រី មួរ សុខ ហួរ អ្នកតំណាងរាស្ត្រមណ្ឌលខេត្ត*

គោរពច្បាប់និងការប្រតិបត្តិព្រះពុទ្ធសាសនា។ អ្នកស្រីបានលើយកចំណុចសំខាន់ៗ ស្តីពីសិទ្ធិស្មើគ្នារវាងស្ត្រីនិងបុរសនៅក្នុងសង្គម ដែលមានសិទ្ធិសេរីភាពពេញលេញ ពីព្រោះស្ត្រី និង កុមារ គឺជាសញ្ញាមួយងាយរងគ្រោះបំផុត ដោយសារខ្វះអាហារសម្រាប់ទទួលទានជាពិសេសខ្វះការអប់រំជាដើម។ ម្យ៉ាងទៀតករណីដីធ្លីរបស់ប្រជាពលរដ្ឋត្រូវបានអ្នកមានអំណាចរឹបអូសយកលក់ឱ្យឈ្មួញបរទេស ហើយរដ្ឋាភិបាលបានធ្វើសម្បទានដី ឱ្យក្រុមហ៊ុនយួនខ្វះការពិចារណារហូតដល់៩៩ឆ្នាំ ចំណុចនេះហើយធ្វើឱ្យរាស្ត្រខ្មែរបាត់បង់ដីធ្លី ជីវិភាពក្រីក្រក្លាយទៅជាខ្ញុំកញ្ជះយួន។

ចំណែកបញ្ហាសុខភាពវិញស្ត្រីនិងកុមារគឺស្លាប់ជារៀងរាល់ថ្ងៃ ដោយរដ្ឋាភិបាលមិនយកចិត្តទុកដាក់ក្នុងការថែទាំសុខភាព និង ប្រើអំពើហឹង្សា រំលោភបំពានទៅលើស្ត្រី-កុមារតុលាការគ្មានយុត្តិធម៌ មន្ត្រីមួយចំនួនប្រព្រឹត្តអំពើពុករលួយជាដើម។

អ្នកស្រីបានមានប្រសាសន៍បន្ថែមទៀតថា អ្នកស្រីបានបង្កើតអង្គការមួយសំរាប់ជួយដល់ស្ត្រីខ្មែរ ឱ្យមានការងារធ្វើ ដើម្បីកាត់បន្ថយភាពក្រីក្រក្នុងសង្គម និងជំរុញស្ត្រីឱ្យមានសេចក្តីក្លាហានក្នុងការធ្វើនយោបាយសំរាប់ចូលរួមដោះស្រាយបញ្ហាផ្សេងៗក្នុងសហគមន៍។

បន្ទាប់ពីអ្នកស្រីតំណាងរាស្ត្រធ្វើសេចក្តីរាយការណ៍រួចមក សមាជិក-កា................**(តទៅទំព័រទី២១)**

# ជីវប្រវត្តិសង្ខេប និង ការតស៊ូរបស់វីរសមណៈ ហែម ចៀវ (តពីលេខមុន)

ពុំមានផ្ទួនពាក្យដដែលៗ សូម្បីតែមួយម៉ាត់ក៏គ្មានដែរ។ ប៉ុន្តែលោកពុំសូវពូកែខាងសរសេរសៀវភៅទេព្រោះសំបូណ៌ពាក្យពេចន៍ និង រវល់បង្រៀនទេសនាពេក។ ចំណែកដំណើរទេសនាចេញបែបដូចគ្រូរបស់លោកបេះបិទនឹងសម្តេចព្រះសង្ឃរាជជួន **ណាត** (តាមប្រសាសន៍របស់លោក ឈឹម-ស៊ុម)។ ត្រង់នេះបានសេចក្តីថា លោកគ្រូព្រះបាទឡាត់ឃោសនានាគ **ហែម ចៀវ** មានលក្ខណៈមិនខុសពីសម្តេចព្រះសង្ឃរាជប៉ុន្មានទេ។ ចំពោះភ្ញៀវពន្លឺលោកទទួលដោយរាក់ទាក់ ឥតរើសមុខថា អ្នកមានអ្នកក្រអ្វីទេ។ ជនណាដែលបានប្រាស្រ័យជាមួយលោកម្តងហើយ ជននោះរមែងចង់ប្រាស្រ័យម្តងទៀតដើម្បីស្តាប់លោកអធិប្បាយវែកញែកអំពីទ្រឹស្តីព្រះពុទ្ធដែលដឹកនាំសត្វលោកអោយដល់ត្រើយនៃសុភមង្គល។ រីឯការបង្រៀនសិស្សវិញ ពូកែខាងពន្យល់ចេះធ្វើអោយសិស្សចូលចិត្តរៀនណាស់ សូម្បីតែសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ ក៏មិនអាចអត់ទ្រាំសរសើរលោកបានដែរ។ សិស្សរបស់លោកស្រឡាញ់លោកគ្រប់ៗគ្នាព្រោះជាសាស្ត្រាចារ្យមិនប្រកាន់ធម៌អគតិ។ បើឃើញសិស្សណាខ្ជិលរៀនសូត្រ លោកតែងតែពោលចំពោះសិស្សនោះដោយសំលេងថ្នមៗ« *ចូរលោកខំរៀនឡើង! កុំបណ្តែតបណ្តោយ ព្រោះយើងជាភេទដែលអ្នកផងគេគោរពរាប់អានគេផ្ញើទាន....... ម៉ែឪយើងនៅក្រោមការត្រួតត្រារបស់បរទេសព្រះពុទ្ធសាសនាត្រូវចុះអន់ថយជាលំដាប់ អក្សរសាស្ត្រយើងស្ទើរសាបសូន្យទៅហើយគួរយើងប្រឹងប្រែងកុំខ្លាចនឿយហត់ ដើម្បីស្រោចស្រង់មាតុភូមិអោយរួចពីខ្ញុំកញ្ជះបារាំង កុំភ្លេចខ្លួនអោយសោះថាយើងជាអ្នកបួសរស់ដោយសារប្រជាជនចិញ្ចឹមត្រូវតែមានចំណេះវិជ្ជាជ្រៅជ្រះទើបធ្វើអោយអ្នកចិញ្ចឹមយើងមានសទ្ធាជ្រះថ្លា។ ចុះបើយើងល្ងង់ខ្លៅតើដឹកនាំគេម្តេចកើតទៅ? តើនរណាគេគោរពរាប់អានយើង?បញ្ហានេះ សូមលោកគិតពិចារណាមើលអោយ*



**Eiffel tower, Paris,** *វីរសមណៈ ហែម ចៀវ និងរាជវាំងខ្មែរ*

*មែនទែនបំណាច់យើងចោលស្រុកចោលស្រែចំការ ម៉ែឪបងប្អូនឪ្យមករៀននៅទីនេះ តើយើងមកដើម្បីអ្វី.... ? យើងសុទ្ធតែកូនអ្នកក្រដូចគ្នាត្រូវជួយគ្នាឡើង កុំធ្វេសប្រហែសអោយសោះ ប្រយ័ត្នគេមើលងាយណា ខ្ញុំគ្មានអ្វីជួយលោកទេមានតែចំណេះវិជ្ជាដ៏ស្តួចស្តើងប៉ុណ្ណោះ។លោក! ការដែលខ្ញុំនិយាយនេះមិនមែនជាការប្រៀនប្រដៅទេ គឺជាការរំលឹកគ្នាទៅវិញទៅមក ក្នុងឋានៈជាកូនអ្នកស្រែ និងអ្នកបួសដូចគ្នា យើងត្រូវតែណែនាំគ្នាដើម្បីស្វែងរកសុភមង្គលអោយប្រទេសយើងដែលបានបាត់បង់ច្រើនឆ្នាំមកហើយ...*»។

ពាក្យដាស់តឿនរបស់លោកគ្រូបាឡាត់ឃោសនានាគ **ហែម ចៀវ** ធ្វើអោយសិស្សសាលាបាលីជាន់ខ្ពស់ស្រលាញ់គ្រូ ហើយខិតខំតស៊ូរៀនសូត្រឥតហ៊ានធ្វេសប្រហែសអ្វីសោះឡើយ។ មិនត្រឹមតែស្រលាញ់ខំរៀនប៉ុណ្ណោះទេថែមទាំងមានការឈឺចាប់នឹងពួកអនានិគមបារាំងខ្លាំងឡើងៗជាលំដាប់ហូរហែធ្វើអោយមជ្ឈដ្ឋានអ្នកស្នេហាជាតិកោតសរសើរ *.......(តទៅទំព័រទី១៩)*

# អ្នកកាសែតជើងចាស់ទស្សនកិច្ចសារមន្ទីរប្រល័យពូជសាសន៍

ក្រុមអ្នកកាសែតជើងចាស់ដែលនៅសេសសល់ជីវិតពីសម័យសង្គ្រាមនៅកម្ពុជាកាលពី ៤០ឆ្នាំមុន នៅថ្ងៃទី២៣មេសានេះ បានធ្វើដំណើរទស្សនាសារមន្ទីរប្រល័យពូជសាសន៍គុកទួលស្លែងវាលពិឃាតបឹងជើងឯក និងសាលាក្តីខ្មែរក្រហម។

ក្រុមអ្នកកាសែតដដែលក៏បានជំរុញឲ្យសាលាក្តីខ្មែរក្រហមពន្លឿនការកាត់ទោស ក្រុមមេដឹកនាំខ្មែរក្រហមឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីយុត្តិធម៌ដល់ជនរងគ្រោះ។ក្រុមអ្នកកាសែតជើងចាស់ចំនួន ៣១នាក់នោះ មានជនជាតិអាមេរិកាំង,អូស្ត្រាលី, អង់គ្លេស,ជប៉ុននិងខ្មែរ ដែលធ្លាប់យកព័ត៌មានអំពីសង្គ្រាមនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧០និងឆ្នាំ១៩៧៥ នៅមុនពេលដែលខ្មែរក្រហមឡើងកាន់អំណាច។ ការមកទស្សនា នៅសារមន្ទីរប្រល័យពូជសាសន៍គុកទួលស្លែងគឺជាទីកន្លែងធ្វើទារុណកម្មរបស់ខ្មែរក្រហម, វាលពិឃាតខ្មែរក្រហមនៅបឹងជើងឯក គឺជាកន្លែងដែលខ្មែរក្រហមយកមនុស្សមកសម្លាប់ចំនួនជាង២ម៉ឺននាក់នៅក្នុងរណ្តៅរួម និង សាលាក្តីខ្មែរក្រហមជាទីកន្លែងដែលមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ កំពុងតែស្ថិតក្នុងដំណើរការជម្រះក្តី។

លោក ខាល រ៉ូប៊ីនសុន (Carl Robinson) អាយុជាង៧០ ឆ្នាំជាអ្នកកាសែតជើងចាស់របស់ទីភ្នាក់ងារព័ត៌មានអាមេរិកឈ្មោះAPកាលពី ៤០ឆ្នាំមុន ដែលកំពុងតែទស្សនា សារមន្ទីរប្រល័យពូជសាសន៍គុកទួលស្លែង បានមានប្រសាសន៍ថា ៖ "នេះគឺជាដំណើររបស់ខ្ញុំលើកទី៣ហើយមកកម្ពុជាតាំងពីឆ្នាំ១៩៧៥មក។ ខ្ញុំមានការរីករាយនៅពេលនេះ ដែលបានមកជួបជុំគ្នា។ សាលាក្តីខ្មែរក្រហមមានកិច្ចការងារយ៉ាងសំខាន់ដែលត្រូវធ្វើ ដើម្បីយុត្តិធម៌ដល់ជនរងគ្រោះ។

លោក កេ សុបណ្ណការ ជានាយកថ្មីរបស់សារមន្ទីរប្រល័យពូជសាសន៍គុកទួលស្លែង បានមានប្រសា



*អ្នកកាសែតជើងចាស់ពិនិត្យមើលរូបថតជនរងគ្រោះ នៅសារមន្ទីរប្រល័យពូជសាសន៍ ទួលស្លែង ក្នុងរាជធានីភ្នំពេញ នៅថ្ងៃ២៣ មេសា ២០១០។*

សន៍អត្ថាធិប្បាយថា ៖ *«ក្រោយពីគាត់បានទស្សនានៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នេះ ហើយគាត់នឹងនាំនាំនូវភាពឈឺចាប់ ដែលប្រជាពលរដ្ឋខ្មែរនៅទូទាំងប្រទេស បានទទួលអំពីរបបប្រល័យពូជសាសន៍ ទៅផ្សព្វផ្សាយទៅដល់ក្រុមគ្រួសារគាត់បងប្អូនមិត្តភក្តិនៅក្នុងប្រទេសកម្ពុជាក៏ដូចជានៅក្នុងពិភពលោកនេះ»។*

អតីតអ្នកទោសខ្មែរក្រហមនៅមន្ទីរស-២១ ឬគុកទួលស្លែង លោក ជុំ មី អាយុ ៧៨ឆ្នាំ ដែលមានជីវិតរស់នៅបានថ្លែងប្រាប់វិទ្យុអាស៊ីសេរី នៅក្នុងបរិវេណមន្ទីរស-២១ នៅក្នុងទីក្រុងភ្នំពេញថា៖ *«ខ្ញុំមិនដឹងថា ពួកអ្នកកាសែតជើងចាស់គាត់អញ្ជើញមកទេ។ តែមកជួបខ្ញុំនេះ ខ្ញុំសប្បាយចិត្តមែនទែន។ ខ្ញុំនិយាយរឿងរ៉ាវនៅក្នុងគុកទួលស្លែងនេះ ឲ្យគាត់បានដឹង។ ...កាលពីមុនខ្ញុំនិយាយយំៗ អត់បានទេ តែយើងបានចូលទៅសាលាក្តី..........យើងនិយាយប្រាប់តុលាការរួចហើយម៉្លោះហើយដូចថា វាធូរ!»*។

ជាមួយគ្នានេះ មន្ត្រីអ្នកនាំពាក្យនៃសាលាក្តីខ្មែរក្រហម លោក ឌឹម សុវណ្ណារុំ ដែលបានដឹកនាំក្រុមអ្នកកាសែតជើងចាស់ធ្វើទស្សនកិច្ច នៅក្នុងសារមន្ទីរប្រល័យពូជសាសន៍ គុកទួលស្លែង ***(តទៅទំព័រទី២២)***

*(តមកពីទំព័រទី១២)* សំរាប់ថ្លឹងថ្លែងអំពីស្នាដៃ និងគុណសម្បត្តិដែលមនុស្សម្នាក់ៗបានបំពេញជូនជាតិ សាសនា ព្រមទាំងសហគមន៍ទាំងមូល អំពីផលល្អ និងផលអាក្រក់។ សមគួរដល់ហេតុដែលសត្វលោកខ្លួនឯងបានអនុវត្ត ជាក់ស្តែង ម្ល៉ោះហើយ ព្រះធម៌ទាំង២ចំណុចនេះ ក៏បានកម្ចាត់បង់នូវកិលេស ដែលលំអៀងទៅរកការស្រឡាញ់ ការស្អប់ខ្ពើម និងភាពមិនស្មោះត្រង់ជាមួយគ្នា ប្រព្រឹត្តអំពើពុករលួយ លួចទ្រព្យសម្បត្តិជាតិ មកធ្វើជារបស់ខ្លួនជាដើម៕

ដោយ ស៊ឹម ចន្ទ្រា

---

*(តមកពីទំព័រទី១៧)*ពីសិស្សសាលាបាលីជាន់ខ្ពស់គ្រប់ៗគ្នា។ក្នុងពេលនោះហើយ ដែលធ្វើឱ្យកិត្តិនាមរបស់លោកគ្រូព្រះបាឡាត់ហែម ចៀវ ក្រអូបគ្រប់ទិសទី។ ស្រុកណាភូមិណា ខេត្តណាក៏ចង់និមន្តលោកទៅសំដែងធម៌ទេសនាដែរ ម្ល៉ោះហើយលោកមានពេលសំរាកតិចណាស់។ **សកម្មភាពដើម្បីជាតិសាសនា** លុះចប់កិច្ចសិក្សាហើយ លោកបានទៅធ្វើជាគ្រូបង្រៀនអក្សរសាស្រ្តជាតិនៅវត្តក្រាំងដូង បង្រៀនព្រះសង្ឃសំរាប់ធ្វើគ្រូតទៅ ប្រកបទៅដោយជោគជ័យជាទីបំផុត។ក្រៅពីពេលបង្រៀនលោកឆ្លៀតសិក្សាខ្លួនឯងទៀត ដើម្បីឈោងចាប់យកសេចក្តីពិតមកទូន្មានខ្លួននិងសិស្សានុសិស្ស ព្រមជាមួយអន្លើដោយឧបាសក ឧបាសិកា ដែលត្រូវការចង់ចេះចង់ដឹង ។ នៅពេលលោកទេសនាមាត់ទទេលើកដំបូងមិនសូវមានអ្នកស្តាប់ច្រើនប៉ុន្មានទេ ព្រោះខ្មែរជាន់ដើមទំលាប់តែទេសន៍តាមសាស្ត្រាស្លឹករឹត។ ម្ល៉ោះហើយចាស់ៗខ្លះប្រកាន់ថា «ធម៌សម័យថ្មីគេមិនចេះស្តាប់ទេ»។ ហេតុការណ៍ទាំងនេះពុំបានធ្វើអោយលោកគ្រូអាចារ្យ ហែម ចៀវ ព្រួយបារម្ភលំបាកចិត្តអ្វីទេ ដោយលោកឈ្លាសវៃក្នុងការពន្យល់ណែនាំ មុនដំបូងវាតែងតែមានប្រតិកម្មដូច្នេះហើយ បើយើងមិនតស៊ូទេ មុខជាមិនបានសំរេចបំណងឡើយ។ ចាប់តាំងពីពេលនោះមក ព្រះអាចារ្យតែងធ្វើសេចក្តីស្និទ្ធស្នាលចំពោះចាស់ៗ ណាដែលមិនសូវចូលចិត្តស្តាប់លោកសំដែងធម៌មាត់ទទេ ជាងអ្នកផងទាំងពួង។ មិនយូរប៉ុន្មានអ្នកទាំងនោះក៏ស្តាប់បានងាយយល់ថែមទាំងសំលេងពិរោះផង ហើយស្រលាញ់លោកហួសនិយាយ ចង់អោយតែលោកអាចារ្យសំដែងធម៌ទេសនារាល់ថ្ងៃសីលនិង បុណ្យទាន ។ នៅឆ្នាំនោះហើយដែលព្រះសង្ឃខ្មែរយើងចាប់ផ្តើមប្រែសូត្រមន្តពីភាសាបាលីមកជាភាសាខ្មែរ ។ ការប្រែមកអោយស្តាប់បាននេះធ្វើអោយអ្នកគិតមិនដល់ជេរត្មះតិះដៀលដល់ព្រះសង្ឃដែលខិតខំប្រែយ៉ាងសំបើម រហូតដល់មានប្តឹងផ្តល់ទៅចូលតុលាការថែមទៀត។ប៉ុន្តែសេចក្តីតស៊ូប្រឹងប្រែងធ្វើការ ដើម្បីអោយសាសនាបានរុងរឿងមានប្រយោជន៍ដល់មហាជន ដោយមិនតបតទៅតាមអំពើពាលល្ងង់ខ្លៅកិច្ចការនោះក៏បានសំរេចជោគជ័យជាស្ថាពររហូតមកដល់សព្វថ្ងៃនេះ។មកដល់ភ្នំពេញលោក អាចារ្យ ហែម ចៀវបានទទួលឋានៈជា «អាចារ្យសាលាបាលីជាន់ខ្ពស់» **(សាស្ត្រាចារ្យ)** មានកំរៃប្រចាំខែ៥០រៀលល្មមនឹងទ្រទ្រង់ជីវភាពឱ្យសំរេចទៅកើត ។លោកគ្រូអាចារ្យ ហែម ចៀវ មានសាមណសក្តិជា «**ព្រះឡាត់ឃោសនានាគ**»របស់សម្តេចព្រះសង្ឃរាជ **ជួន-ណាត**កាលលោកនៅជាព្រះពុទ្ធឃោសាចារ្យ មុខងារថ្មីនេះពុំអាចទាញកំលាំងចិត្តស្នេហាជាតិរបស់លោកឱ្យភ្លេចបានឡើយ លោករឹងរឹតតែខំរៀនខំអានសៀវភៅខ្មែរបរទេស ដែលសំខាន់ៗ ស្តីអំពីរឿងសាសនា នយោបាយ សេដ្ឋកិច្ច អក្សរសាស្រ្ត ទស្សនវិជ្ជាគ្រប់ទិវារាត្រី ឥតបីបណ្តោយឱ្យពេលវេលាកន្លងផុត ដោយពុំបានធ្វើអ្វីជាប្រយោជន៍ទេ។ ក្រៅពីការសិក្សាបង្រៀនសិស្សទេសនា ពន្យល់ខ្មែរល្ងិតល្ងង់ ព្រះបាឡាត់ឃោសនានាគ ហែម ចៀវ ឆ្លៀតពេលទៅប្រាស្រ័យទាក់ទងនឹងវរជនធំៗ ដែលស្នេហាមាតុភូមិជាច្រើនទៀត ដូចជាលោក*ប៉ាច ឈឺន, សឺង ង៉ុកថាញ់ , ជុំ -មួង, នួន-ដួង និង ស៊ឹម-វ៉ា* ។ល។...........*(តទៅទំព័រទី២៤)*

# ខ្មែរក្រោមភាគច្រើនមិនអាចទៅលេងស្រុកពេលចូលឆ្នាំ

ប្រភពពីក្រុមអ្នកការពារសិទ្ធិ មនុស្សខ្មែរក្រោមឲ្យដឹងថាមានប្រជាពលរដ្ឋខ្មែរក្រោមតិចតួចបំផុតដែលបានចូលទៅកម្សាន្តសប្បាយរីករាយជួបជុំញាតិសន្តានរបស់ខ្លួននៅក្នុងទឹកដីខ្មែរកម្ពុជាក្រោម ដែលកំពុងកាន់កាប់ដោយវៀតណាមឬហៅថាវៀតណាមខាងត្បូង កាល ពីអំឡុងពេលចូលឆ្នាំប្រពៃណីខ្មែរកន្លងទៅនេះ។

អ្នកដែលបានចូលទៅដល់ទីនោះទៀតសោតបានរាយការណ៍មកថាអាជ្ញាធរវៀតណាម បានរឹតត្បិតដកហូតយកលិខិតឆ្លងដែន ហើយបានធ្វើសកម្មភាពតាមដានជាប្រចាំ និងមិនឲ្យស្នាក់អាស្រ័យយូរតាមចិត្តចង់ឡើយ។

ព្រះតេជគុណ ចៅ សុខ មានស្រុកកំណើតនៅស្រុកស្វាយទង ដែលបានឃ្លាតឆ្ងាយពីភូមិកំណើតរបស់ព្រះអង្គអស់រយៈពេល៣ឆ្នាំ កន្លងមកហើយ ក្រោយការភៀសខ្លួន មានថេរដីកាថា ព្រះអង្គបាននិមន្តចូលសួរសុខទុក្ខញាតិញោមនៅទីនោះ ប៉ុន្តែទៅដល់ត្រូវគេដកហូតយកលិខិតឆ្លងដែនអស់ ១យប់ ១ថ្ងៃ ហើយក្រោយមកទៀត គេបានដាក់កម្លាំងតាមដាន ហើយបានបណ្តេញព្រះអង្គឲ្យចេញមកវិញ មុនគំរោងនៃការគង់នៅរបស់ព្រះអង្គ។

ព្រះតេជគុណចៅ សុខ មានថេរដីកា៖ «*ហើយត្មាមកហ្នឹង ដោយសារគេមិនចង់ឲ្យនៅទៀត ទើបត្មាឡើងមក។ អាត្មាមិនទាន់សាកសួរសុខទុក្ខបងប្អូនអស់ផង ស្រាប់តែគេថាមិនចង់ឲ្យអាត្មានៅទៀត។ គេដេញយើងចេញតែម្តង។ ត្មាគិតថានៅបានប្រហែលជាមួយសប្តាហ៍ទៀតគ្រាន់ដើរលេង សួរសុខទុក្ខបងប្អូន ញាតិមិត្តឲ្យគ្រប់។ រាំងស្ទះដំណើរអ៊ីចឹងទៅ ត្មាមិនចង់ឲ្យប៉ះពាល់ដល់អ្នកស្រុក អ្នកភូមិនៅទីនោះ*»។

ព្រះតេជគុណមួយអង្គទៀត ព្រះនាម ថាច់ ស៊ីណាន ដែលបានភៀសខ្លួនមកកម្ពុជា ហើយបន្តការសិក្សានៅប្រទេសថៃ ផ្នែកវិទ្យាសាស្ត្រសង្គម បានរៀបរាប់ថា ព្រះអង្គបាននិមន្តចូលទៅក្នុងស្រុកឡុងហោដែលជាភូមិស្រុកកំណើតព្រះអង្គនៅកម្ពុជាក្រោមនោះ ហើយនៅពេលព្រះអង្គព្យាយាមស្នាក់អាស្រ័យនៅ ក្នុងវត្តមួយ ព្រះចៅអធិការវត្តក៏បានបណ្តេញព្រះអង្គចេញ ហើយក្រោយមក នៅពេលទៅដល់ភូមិ ក្រុមប៉ូលិសយៀតណាមស្លៀកពាក់ស៊ីវិល ក៏បានតាមដានសកម្មភាពព្រះអង្គមិនឈប់។



*យុវជន យុវតីខ្មែរក្រោម រាំកំសាន្ត នៅពេលបុណ្យចូលឆ្នាំខ្មែរ*

ព្រះតេជគុណ ថាច់ ស៊ីណាន មានថេរដីកា ៖ «*ញាតិញោមគាត់ប្រាប់កាល អាត្មាទើបចុះទៅដល់ទីក្រុងព្រៃនគរ មានគេទៅចាំដូចជាគំរាមថា បើអាត្មាចុះទៅគេហ្នឹងចាត់ការ។ ពេលទៅដល់ភូមិស្រុក ឥតមានអ្វីផង ឥតមាននរណាគេហ៊ានមកអើតសួរអីទេ ប៉ុន្តែគេនៅពីខាងក្រោយ។ អាត្មានិមន្តទៅណាគេថតរូប គេមានភ្នាក់ងារសម្ងាត់នៅខាងក្រោយ*»។

ប្រភពពីសមាគមការពារសិទ្ធិមនុស្សខ្មែរក្រោមបានឲ្យដឹងថា មានខ្មែរក្រោមប្រហែល ៥%ប៉ុណ្ណោះដែលបានចូលទៅសួរសុខទុក្ខញាតិសន្តាន នាឱកាសបុណ្យចូលឆ្នាំខ្មែរ។លោក ថាច់ សុង ប្រធានសមាគមខ្មែរកម្ពុជាក្រោម...? បានថ្លែងថា ភាគច្រើននៃប្រជាជនខ្មែរក្រោម ដែលមកដល់កម្ពុជាសុទ្ធសឹងតែជាអ្នកគេចវេះនៃការតាមចាប់ខ្លួន ដូច្នេះហើយពួកគាត់មិនមានលិខិតស្នាមដើម្បីដើរហើរនិងត្រឡប់ចូលទៅស្រុកឡើយគេបារម្ភអំពីការតាមចាប់ខ្លួន***(តទៅទំព័រទី២៨)***

*(តមកពីទំព័រទី១៦)* លើកជាសំនួរសួរទៅអ្នកស្រី ទាក់ទងនឹងគោលនយោបាយរបស់គណបក្សសមរង្សី ក្នុងការដោះស្រាយនូវវិបត្តិផ្សេងៗដែលកើតមាននៅប្រទេសកម្ពុជាសព្វថ្ងៃនេះ ដូចជាបញ្ហាដីធ្លី សុខភាព ការអប់រំ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងជនអន្តោប្រវេសន៍។ អ្នកស្រីបានជំរាបជូនអង្គប្រជុំថា អ្នកតំណាងរាស្ត្រគណបក្សសមរង្សីទាំង២៦រូបនឹងខិតខំប្រឹងប្រែងតស៊ូគ្រប់មធ្យោបាយទាំងអស់ ក្នុងការរកដំណោះស្រាយជូនដល់ប្រជាពលរដ្ឋខ្មែរឱ្យរួចផុតពីភាពក្រីក្រការរំលោភបំពានសិទ្ធិសេរីភាពការប្លន់យកដីធ្លីពីសំណាក់អ្នកមានអំណាច និងរដ្ឋាភិបាល បច្ចុប្បន្ន។

នេះជាលើកទីពីរហើយ ដែលអ្នកស្រីតំណាងរាស្ត្រ បានជួបសំណេះសំណាលជាមួយបងប្អូនខ្មែរយើង នៅវត្តខេមរង្សី។ អ្នកស្រីក៏បានអំពាវនាវដល់បងប្អូនខ្មែរទាំងអស់ ឱ្យមានស្មារតីរឹងប៉ឹង ដើម្បីតស៊ូបញ្ចេញមតិស្វែងរកពន្លឺយុត្តិធម៌និងទាមទារសិទ្ធិជូនដល់ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅរងទុក្ខវេទនា៕

ដោយ ថាច់ សុរិយា

---

*(តមកពីទំព័រទី៧)* ឱ្យក្លាយទៅជាបុគ្គលដែលគួរគោរពនៅក្នុងសង្គមជាតិ។

ការត្រាស់ដឹងរបស់ព្រះពុទ្ធ គឺជាឱសថមួយដែលមានតំលៃមិនអាចកាត់ថ្លៃបាន ក្នុងការព្យាបាលជម្ងឺផ្លូវចិត្តនៃមនុស្សទូទៅ ហើយក៏ជាត្រីវិស័យមួយដែរ សំរាប់ចង្អុលបង្ហាញផ្លូវទៅរកសុខសន្តិភាពដល់សព្វសត្វទាំងអស់ នៅលើសកលលោកនេះ គឺឱ្យលះបង់អាវុធ ចាប់យកព្រះធម៌ដើម្បីស្ថាបនាកម្លាំងសាមគ្គីឱ្យបានរឹងមាំ ក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនិងសង្គមជាតិឆ្ពោះទៅកាន់ភាពរីកចំរើនរុងរឿង ប្រកបដោយសីលធម៌ គុណធម៌ ព្រហ្មវិហារធម៌និងភាពថ្លៃថ្នូរនៃមនុស្សជាតិ។



*បុណ្យវិសាខបូជាអន្តរជាតិ នៅទីក្រុងបាំងកកប្រទេសថៃ ឆ្នាំ២០០៩*

ដោយសារភាពច្បាស់លាស់ នៃការយល់ដឹងរបស់មនុស្សតាមទ្រឹស្តីព្រះពុទ្ធសាសនានេះហើយ ទើបអង្គការសហប្រជាជាតិទទួលស្គាល់បុណ្យវិសាខបូជា កាលពីថ្ងៃទី១៥ខែ១២ឆ្នាំ១៩៩៩ជាផ្លូវការ ហើយក្នុងឆ្នាំ២០១០នេះ អង្គការសហប្រជាជាតិបានរៀបចំកម្មវិធីបុណ្យលក្ខណៈអន្តរជាតិនៅទីក្រុងបាងកក ប្រទេសថៃ នៅថ្ងៃទី២៣រហូតដល់ថ្ងៃទី២៥ ដោយមានការនិមន្ត-អញ្ជើញចូលរួមពីព្រះសង្ឃនិងពុទ្ធបរិស័ទទូទាំងសកលលោក។ ចំពោះប្រទេសកម្ពុជាឆ្នាំនេះវិញ បានរៀបចំបុណ្យវិសាខបូជាយ៉ាងធំធេងនៅប្រាសាទអង្គរវត្ត ខេត្តសៀមរាប នាថ្ងៃទី២៨ខែមេសាឆ្នាំ២០១០កន្លងទៅហើយនេះ។ ដោយឡែកនៅឯដែនដីកម្ពុជាក្រោមវិញ ប្រជាពលរដ្ឋខ្មែរក្រោមទាំងអស់ ដែលជាអ្នកគោរពប្រតិបត្តិព្រះពុទ្ធសាសនាតាំងពីបុរាណកាលមកនោះ។ ព្រះសង្ឃ គណៈកម្មការ អាចារ្យវត្ត និងពុទ្ធបរិស័ទនៅគ្រប់វត្តចំនួនជាង ៥០០វត្តនឹងធ្វើពិធីបុណ្យវិសាខបូជាទៅតាមប្រពៃណីព្រះពុទ្ធសាសនាជារៀងរាល់ឆ្នាំលុះដល់ថ្ងៃ១៥កើត ពេញបូរមី ខែពិសាខ ដោយមានការនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត សំដែងធម៌ទេសនា ស្វាធ្យាយធម៌បទរំលឹកគុណបារមីព្រះពុទ្ធ នៅពេលព្រះអង្គប្រសូតិ, ត្រាស់ដឹង, យាងចូលកាន់បរិនិព្វាន រួចប្រគេនចង្ហាន់ដល់ព្រះសង្ឃ។ នេះហើយ គឺជាមហាកុសលមួយសំរាប់ពុទ្ធបរិស័ទជាអ្នកទ្រទ្រង់ថែរក្សាខឿនព្រះពុទ្ធសាសនាឱ្យបានគង់វង្សគ្រប់៥០០០ព្រះវស្សានិងគឺជាការដឹងគុណចំពោះព្រះពុទ្ធបរមគ្រូផងដែរ៕ ***ដោយ ស៊ឹម ចន្ទ្រា***

***(តមកពីទំព័រទី១៨)*** ឬមន្ទីរស-២១ បានមានប្រសាសន៍ថា ៖ *«ពិភពលោកឥឡូវនេះគ្មានជញ្ជាំងទៀតទេ ហើយអ្នកដែលធ្វើឲ្យពិភពលោកនៅគ្រប់ទីកន្លែងបានដឹងឮគឺពួកគាត់នេះហើយគឺជាអ្នកកាសែតនេះហើយដែលជាប្រមុះ ជាមាត់ ជាភ្នែក ដើម្បីឃើញ ដើម្បីនិយាយ ដើម្បីប្រាប់ទៅពិភពលោក។ ដូច្នេះសំខាន់មែនទែន ដែល៤០ឆ្នាំក្រោយមកគាត់ត្រឡប់មកប្រទេសកម្ពុជាវិញគាត់មកមើល។ទន្ទឹមនឹងឃើញប្រវត្តិដ៏ជូរចត់ក៏គាត់ឃើញការរីកចំរើនរបស់ប្រទេសយើងផងដែរ»*។

របបខ្មែរក្រហមរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គេបានប៉ាន់ស្មានថា បានសម្លាប់មនុស្សចំនួនជិត ២លាននាក់ ដោយសារការធ្វើទារុណកម្មធ្វើការងារបាក់កម្លាំង អត់បាយ និងគ្មានថ្នាំព្យាបាលនៅទូទាំងប្រទេសកម្ពុជា។ ក្រុមអ្នកកាសែតជើងចាស់ចំនួន៣១នាក់ ដែលបានមកជួបជុំគ្នាលើកដំបូងក្នុងរយៈពេល ៤០ឆ្នាំ ក្រោយពីសង្គ្រាមទសវត្សរ៍ឆ្នាំ១៩៧០និងឆ្នាំ១៩៧៥កន្លងមកនេះ បានជួបជុំគ្នាក្នុងប្រទេសកម្ពុជា និងធ្វើដំណើររួមគ្នារយៈពេលជិត ១សប្ដាហ៍។

ពួកគាត់បានជួបជុំក្នុងពិធីជប់លៀងគោរពវិញ្ញាណក្ខន្ធដល់អ្នកកាសែតនានាដែលបានស្លាប់កាលពីសម័យសង្គ្រាមទស្សនាមន្ទីរស-២១វាលពិឃាដបឹងជើងឯកនិងសាលាក្ដីខ្មែរក្រហម នៅក្នុងដំណើរទស្សនកិច្ចក្នុងប្រទេសកម្ពុជាតាំងពីថ្ងៃទី២០ ខែមេសាថ្មីៗនេះ ហើយពួកគាត់មានគម្រោងការចាកចេញពីប្រទេសកម្ពុជាវិញ នៅចុងសប្ដាហ៍នេះ៕

*ប្រភព RFA*

## ពិធីរំឭកគុណទេសបារមីនិងវិញ្ញាណក្ខន្ធវីរបុរសខ្មែរនៅសៀមរាប

ព្រះសង្ឃនៃព្រះពុទ្ធសាសនា អ្នកបញ្ចូលរូបបែបអបិយជំនឿ និងមហាជនមកពីខេត្តក្រុងមួយចំនួននៃប្រទេសកម្ពុជារាប់ពាន់នាក់ បានជួបជុំគ្នាធ្វើពិធីបុណ្យមួយ ដើម្បីបួងសួងរំឭកដល់គុណទេសបារមី ម្ចាស់ទឹក ម្ចាស់ដី និងវិញ្ញាណក្ខន្ធវីរបុរស វីរនារីខ្មែរ នឹងដើម្បីសុំសេចក្ដីសុខសន្តិភាពផង នៅមុខប្រាសាទភិមានអាកាស នៃបរិវេណអង្គរធំ ខេត្តសៀមរាប កាលពីព្រឹកថ្ងៃព្រហស្បតិ៍ ទី២២ រហូតដល់ព្រឹកថ្ងៃទី២៣ ខែមេសា។

អនុប្រធានគណៈកម្មការរៀបចំពិធីបួងសួងនោះ លោក រស់ ដោយញញឹម បានមានប្រសាសន៍ថា ពិធីនោះ គឺធ្វើក្នុងបំណងតបស្នងសងគុណដល់អតីតព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ វិស្វករ និងស្ថាបត្យករខ្មែរជាច្រើន ដែលជាអ្នកកសាងប្រាសាទថ្មបន្សល់ទុកនៅរហូតដល់បច្ចុប្បន្ន ដើម្បីបញ្ជូនកុសលផលបុណ្យដល់បុព្វបុរសទាំងនោះផងដែរ។ លោក រស់ ដោយញញឹម បានបញ្ជាក់ថា ៖ *«ធ្វើនេះគឺបំណងរំឭកដល់គុណបុណ្យដ៏ខ្ពង់ខ្ពស់របស់ព្រះរាជាគ្រប់ជំនាន់ ជាអ្នកបានបូជាជីវិត ប្រជារាស្ត្រក្ដី បណ្ឌិតក្ដី អ្នកប្រាជ្ញក្ដី វិស្វករក្ដី វិចិត្រករក្ដី គ្រប់ជំនាន់ដែលលោកបានស្ថាបនាឡើង ដូចជាអង្គរ... សម្រាប់តម្កល់ទុកឲ្យកូនខ្មែរជំនាន់ក្រោយបានឃើញ ហើយបូជាទុករចនាបថយ៉ាងស្អាត ដូចជារូបចម្លាក់ ដើម្បីបំផុសដួងវិញ្ញាណក្ខន្ធលោកងើបឡើង ឬក៏ថ្វាយកុសលផលបុណ្យដល់គាត់ ក្រែងគាត់មានបាបកម្មណាមួយ ធ្លាក់ទៅដល់អបាយភូមិទាំង៤ក្ដី យើងមើលមិនឃើញ យើងរំឭកគុណដើម្បីឲ្យផុតកម្មពៀរទៅ ឬក៏កូនខ្មែរដែលមានកម្មពៀរច្រើនជំនាន់ហ្នឹង ឲ្យរួចកម្មពៀរទៅ»*។

ក្នុងពិធីបុណ្យនោះគេមានរៀបចំពិធីរាប់បាត្រព្រះសង្ឃ ការសែនក្រុងពាលីដល់ម្ចាស់ទឹក ម្ចាស់ដី ពិធីបួងសួងថ្វាយដល់អច្ឆរិយ ពិធីអន្ទងព្រលឹងបុព្វបុរស និងសែនដល់វិញ្ញាណក្ខន្ធកងទ័ពដែលបានស្លាប់ដើម្បីជាតិមាតុភូមិ និងមានសម្ដែងជាក្បាច់គុនខ្មែរល្បុក្កតោទៀតផង៕

*ប្រភព RFA*

# ទំនាក់ទំនងរវាងសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក

ដូចដែលធ្លាប់បានលើកឡើងរួចហើយថា នៅឆ្នាំ២០០៣ សហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិក មើលមុខគ្នាមិនចំ មូលហេតុ គឺមកពីអាមេរិកធ្វើសង្គ្រាមនៅ Irak ហើយធ្វើឲ្យអឺរ៉ុបប្រេះឆាគ្នា។ Anglais Espagne និង Italie គាំទ្រអន្តរាគមន៍យោធារបស់អាមេរិក រីឯបារាំងនិង Allemand វិញប្រឆាំង។ ម្យ៉ាងវិញទៀត គឺនៅឆ្នាំ២០០៣នោះហើយ ដែលសហភាពអឺរ៉ុបត្រៀមខ្លួនទទួលបណ្តាប្រទេសអឺរ៉ុបខាងកើត ឲ្យចូលជាសមាជិក។ បណ្តាប្រទេសសមាជិកថ្មីថ្មោងទាំងនេះ ដែលបានឋិតនៅក្រោមក្រញាំសហភាពសូវៀតជាច្រើនទសវត្សរ៍ នៅមិនទុកចិត្តរុស្ស៊ី ត្រូវការឲ្យអាមេរិកការពារពួកគេ ម្ល៉េះហើយពួកគេនាំគ្នាទៅគាំទ្រភ្លាមភ្លែតសង្គ្រាមអាមេរិកនៅ Irak។ ទាំងនេះធ្វើឲ្យសហភាពអឺរ៉ុបបែកបាក់ប្រេះឆាគ្នាកាន់តែខ្លាំងនិង ធ្វើឲ្យអឺរ៉ុបនិងអាមេរិកកាន់តែមិនចុះសម្រុងគ្នា។

ប៉ុន្មាន ឆ្នាំក្រោយមក គឺនៅចុងឆ្នាំ២០០៨ សហរដ្ឋអាមេរិករបស់លោក Bush លែងអុងអាត់ លែងប្រកាន់យកជំហរឯកតោភាគីនិយម នៅលើឆាកអន្តរជាតិដូចពេលមុនទៀតហើយ។ ពីព្រោះស្ថានភាពនៅ Irak មិនប្រព្រឹត្តទៅដូចទីក្រុង Washington បានគ្រោងទុកទេ ពីព្រោះជ័យជំនះ តាមរយៈការបោះឆ្នោតប្រជាធិបតេយ្យរបស់ចលនាអ៊ីស្លាមជ្រុលនិយមHamas នៅដែនដីPalestine បានបើកភ្នែកលោក Bush ឲ្យយល់ថា គេមិនអាចបង្ខំភូមិភាគដើមបូព៌ាឲ្យទទួលយកលទ្ធិប្រជាធិបតេយ្យងាយៗបានទេ។ អ៊ីចឹងហើយបានជាអាមេរិករបស់លោក Bush មានចរិតស្លូតវិញ ស្លូតជាងនៅឆ្នាំ២០០៣ដោយបានងាកមកឲ្យតម្លៃដល់ អ.ស.ប ជាអាទិ៍ក្នុងសំណុំរឿងនុយក្លេអ៊ែរ របស់កូរ៉េខាងជើងនិងរបស់ Iran។ នៅក្នុងបរិបទបែបនេះ អឺរ៉ុបនិងអាមេរិកក៏ខិតចូលជិតគ្នាវិញ។

ប៉ុន្តែ នៅឆ្នាំ២០០៨ ឆ្នាំដែលលោក Bushជិតអស់អាណត្តិប្រធានាធិបតី ទោះជាទំនាក់ទំនងរវាងអាមេរិកនិងអឺរ៉ុបល្អប្រសើរជាងមុនក្តីក៏នៅមានសល់ច្រើនណាស់មូលហេតុស្មុគស្មាញដែលបន្តធ្វើឱ្យភាគីទាំងពីរមិនអាចស្និទ្ធស្នាលគ្នាបាន ដូចកាលសម័យសង្គ្រាមត្រជាក់បានឡើយ។ ជាបឋមនៅខាងសហភាពអឺរ៉ុប អឺរ៉ុបមិនយល់ឃើញនិងធ្វើតាមអាមេរិកទេ នៅចំពោះមុខចលនាភេរវនិយម។រដ្ឋការលោក Bush ធ្វើសង្គ្រាមប្រឆាំងភេរវកម្ម ដូចខ្លួនបានធ្វើសង្គ្រាមកំចាត់ពួក Nazi Allemand កាលសម័យសង្គ្រាមលោកលើកទីពីរបានន័យថា ចំពោះអាមេរិករបស់លោក Bush ឲ្យតែជាភេរវជន គឺសុទ្ធតែជាពួកតំណាងសភាវៈអាក្រក់ទាំងអស់ ទោះជាអ្នកនោះជាអ្នកទាមទារផ្តាច់ទឹកដីនិយម ដូចពួកTchéchènes ឬក៏ជាពួកសកម្មជនAl-Qaïda តាំងនាមឲ្យសាសនាអ៊ីស្លាមជ្រុលនិយមក៏ដោយ។



*ទង់ជាតិសហរដ្ឋអាមេរិក និងទង់សហភាពអឺរ៉ុប*

ម្យ៉ាងវិញទៀត អឺរ៉ុបក្តៅចិត្ត ដោយហេតុតែអាមេរិក ដែលជាជើងឯកនៃពិភពភាវូបនីយកម្ម ចេះតែបង្ខិតបង្ខំគេឯង ឲ្យទទួលចក្ខុនិមិត្តនៃទីផ្សារសេរីរបស់ខ្លួនជាពិសេស នៅពេលចរចាក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក OMC ម្តងៗ។ ចំណុចមួយទៀតដែលអឺរ៉ុបមិនចុះសម្រុងជាមួយអាមេរិក គឺសុបិនរបស់លោកBushក្នុងការធ្វើឲ្យសន្តិភាព ***(តទៅទំព័រទី២៦)***

*(តមកពីទំព័រទី១៩)* ដើម្បីរិះរកមធ្យោបាយរំដោះជាតិ អោយរួចពីខ្ញុំបារាំង។ វេលាថ្ងៃមួយ លោក **សឺង ង៉ុកថាញ់** បានទៅជួបព្រះបាឡាត់ **ហែម ចៀវ** ហើយប្រគេនដំណឹងថា៖លោកគ្រូព្រះបាលាត់ បំណងយើងជិតបានសំរេចហើយ!ពរ!ជិតបានសំរេចអីលោក?ព្រះបាឡាត់ **ហែម ចៀវ** ចោទសំនួរដោយងឿងឆ្ងល់ ។

លោក**សឺង ង៉ុកថាញ់** ញញឹមបន្តិច រួចបន្លឺវាចា៖

-ករុណាម្ចាស់ សព្វថ្ងៃនេះ ដូចជាលោកគ្រូអាចារ្យដឹងស្រាប់ហើយទាហានជើងក្រហម និង ជើងខ្មៅមិនត្រូវគ្នាទេដោយសារបារាំងចេះតែចាក់រុកអោយបែកសាមគ្គី។ ឥឡូវនេះបារាំងបានចាត់ឱ្យខ្ញុំករុណានិមន្តព្រះសង្ឃទេសនាពន្យល់ពួកទាហានទាំងនុ៎ះ ដើម្បីកុំឱ្យទាស់គ្នាទៀត។ ក្នុងពេលនេះ ខ្ញុំករុណាសូមនិមន្តលោកអាចារ្យហើយ។

- យី! ម៉េចក៏លោកមិននិមន្តលោកអាចារ្យ ប៉ាង-ខាត់, សូ-ហាយ ផង ?ករុណា ខ្ញុំនិមន្តតែទាំងអស់អង្គហ្នឹង មិនអោយសល់ទេ តែធ្វើយ៉ាងណាកុំអោយពួកវាដឹងឬសង្ស័យក្រែងទៅទេសនាឬ ពន្យល់ទៀតមិនកើត។ពរ ការនេះមិនថ្មីទេ ចំពោះរូបអាត្មាភាព តែអាត្មាព្រួយក្រែងខ្មែរយើងខ្លះចង់បានបុណ្យសក្តិពីពួកបារាំង ហើយយកការណ៍ទៅអោយបារាំងវិញ!

- ករុណាវាពិតហើយ តែយើងមិនត្រូវខ្លាចទេ។ យើងត្រូវខំពុះពារគ្រប់ឧបសគ្គ ទើបបំណងរបស់យើងបានសំរេច។

- ពរ ត្រូវហើយលោក! អាត្មាមិនដែលនឹកខ្លាចដល់គ្រោះថ្នាក់អ្វីផ្ទាល់ខ្លួនទេ គឺខ្លាចបែកការសំងាត់របស់ក្រុមបដិវត្តន៍យើង! អាត្មាមិនមែនជាអ្នកនយោបាយដូចលោកទេគឺជាអ្នកបួសគ្រាន់តែទេសនាពន្យល់ពុទ្ធបរិស័ទអោយស្គាល់ អោយដឹង អោយយល់អោយអនុវត្តតាមព្រះសម្ពុទ្ធទេតើ! បើស្លាប់ ដើម្បីជាតិ សាសនា អាត្មាក៏មិនតូចចិត្តដែរ ធ្វើម៉េចវាសនាមនុស្សវាត្រូវទទួលដូច្នេះ!

- ត្រូវហើយលោកគ្រូម្ចាស់ការពិត ដែលយើងត្រូវនិយាយនោះ យើងត្រូវតែនិយាយអោយប្រជារាស្ត្រដឹង។លេងធម៌និយមឯបអបមុខជារាស្ត្រលិចលង់ដដែល។ ខ្ញុំករុណាសុខចិត្តបូជាជីវិតជូន ជាតិ សាសនា អស់ហើយ ពុំមានខ្លាចស្លាប់ទេ! ព្រោះយើងកើតមករមែងស្លាប់ទៅវិញជាធម្មតា។ ខ្ញុំករុណាគិតសុំថ្វាយបង្គំលាសិនហើយ!

- កុំប្រញាប់អញ្ជើញពេកលោក!

- ខ្ញុំករុណាមានការច្រើនទៀត ដែលត្រូវធ្វើ! ចាំថ្ងៃក្រោយ ចាំដដែកអោយយូរបន្តិច ។

ពរ! អញ្ជើញចុះលោក សូមអោយបានសុខ! លោកសឺងង៉ុក ថាញ់ក៏ក្រាបបង្គំលាព្រះអាចារ្យវិលទៅលំនៅវិញប្រកបដោយទឹកចិត្តរីករាយជាអនេក ។

ក្រុមខ្មែរអ្នកភ្ញាក់រលឹកចេះតែដើរឃោសនាបញ្ចុះបញ្ចូលរាស្ត្រព្រះសង្ឃ គ្រប់និគមជនបទអោយមានការឈឺចាប់ឡើង។ លោក **ប៉ាច ឈឺន** មាននាមល្បីខ្ទរខ្ទារដោយធ្វើជាចាងហ្វាងសារពត៌មាន«នគរវត្ត » មានអ្នកអានសុទ្ធជាអ្នកស្រលាញ់ជាតិពិតប្រាកដ។ ប្រជារាស្ត្រនិងព្រះសង្ឃ បានគាំទ្រសារពត៌មាននេះ យ៉ាងពេញទំហឹង។ ចំណែកខាងព្រះសង្ឃ ដែលខំតស៊ូយ៉ាងស្វិតស្វាញមិនខ្លាចស្លាប់ ដើម្បីមាតុភូមិរស់នោះ គឺលោកអាចារ្យ **ប៉ាង ខាត់** សាស្ត្រាចារ្យភាសាសំស្រ្កឹត លោកគ្រូអាចារ្យ **សូរ ហាយ** ក្រុមជំនុំព្រះត្រៃបិដក លោកគ្រូអាចារ្យ **ខៀវ ជុំ** គង់នៅវត្តលង្កា ព្រះអាចារ្យ **ហែម ចៀវ** សាស្ត្រាចារ្យភាសាបាលី និង សាមណសិស្សនៅសាលាបាលីជាន់ខ្ពស់ជាច្រើនអង្គទៀតជួយផង។ ព្រះសង្ឃទាំងអស់អង្គនេះហើយដែលធ្វើអោយទាហានខ្មែរភ្ញាក់រលឹកលែងឈ្លោះទាស់ទែងគ្នាដោយខុសបទ។ ក្រុមទាហានបារាំងកាចសាហាវណាស់ មិនស្គាល់ច្បាប់ទំលាប់អ្វីសោះ។បងប្អូនខ្មែរយើងស្អប់ខ្ពើម*(តទៅលេខក្រោយ)*

## អាមេរិកត្រៀមប្រកាសឱ្យកាត់បន្ថយបរិមាណអំបិលក្នុងម្ហូបអាហារ ព្រោះជាមូលហេតុនៃជំងឺលើសឈាម




កាសែតវ៉ាស៊ីនតោនប៉ុស្ដិ៍បានផ្សាយកាលពីថ្ងៃទី១៩ មេសាដោយយោងតាមសំដីរបស់មន្ត្រីជាន់ខ្ពស់ក្នុងស្ថាប័នស្បៀងអាហារនិងឱសថសហរដ្ឋអាមេរិក(FDA) ថា FDA មានគំរោងកាត់បន្ថយបរិមាណបរិភោគអំបិលនៃជនជាតិអាមេរិកឱ្យថយចុះ ក្រោយពីលទ្ធផលស្រាវជ្រាវបញ្ជាក់ឱ្យដឹងថា សារជាតុសូដ្យូមនៅក្នុងអំបិល គឺជាកត្តាដែលធ្វើឱ្យមានអ្នកស្លាប់បាត់បង់ជីវិត ដោយជំងឺមានសម្ពាធឈាមខ្ពស់ (លើសឈាម) និងជំងឺបេះដូងមានចំនួនកើនឡើងក្នុងមួយឆ្នាំៗ។ នៅក្នុងរបាយការណ៍កាសែតដដែលបញ្ជាក់ថា គំរោងកាត់បន្ថយនេះនឹងឆ្ពោះទៅរកការកំណត់បរិមាណសារជាតុសូដ្យូមនៅក្នុងអាហារជាលើកដំបូង ក្នុងប្រវត្តិសាស្ត្រសហរដ្ឋអាមេរិកបាននៅក្នុងឆ្នាំនេះ ខណៈពេលក្រុមហ៊ុនផលិតម្ហូបអាហារ និងភេសជ្ជៈជាច្រើននៅសហរដ្ឋអាមេរិកបានចាប់ផ្ដើមបន្ថយបរិមាណសារជាតុសូដ្យូមនៅក្នុងផលិតផលរបស់ខ្លួនមួយចំនួន ហើយដូចជាភេសជ្ជៈប៊ិបស៊ីក៏បានប្រកាសតាំងពីខែមុនថា កាត់បន្ថយសារជាតុសូដ្យូមក្នុងផលិតផលឱ្យថយចុះ២៥%នៅក្នុងឆ្នាំ២០១៥ ៕

## បរិភោគសាច់អាំងឆ្អិនខ្លាំងពេក អាចគ្រោះថ្នាក់នឹងកើតជំងឺមហារីកបាន



តាមរយៈអ្នកវិទ្យាសាស្ត្រមហាវិទ្យាល័យថេកសាសបានឲ្យដឹងថា ការបរិភោគសាច់សត្វច្រើន ជាពិសេសធ្វើឲ្យឆ្អិនពេកអាចប្រថុយនឹងការកើតជំងឺមហារីកក្រពះរំលាយអាហារបានដោយងាយ ដោយហេតុថា ការចៀន ឬអាំង សាច់ឲ្យឆ្អិនក្រៀមខ្លាំងពេកធ្វើឲ្យកើតសារជាតុគីមីម៉្យាងបង្កឲ្យកើតជំងឺមហារីកបាន។

តាមលទ្ធផលសិក្សាដែលបានធ្វើទៅលើមនុស្សចំនួន ១៧០០ នាក់ ក្នុងរយៈពេល ១២ ឆ្នាំ ធ្វើឡើងនៅកន្លែងប្រជុំពិគ្រោះវិនិច្ឆ័យរោគមហារីកក្នុងសហរដ្ឋអាមេរិកបានបញ្ជាក់ថា អ្នកដែលបានហូបសាច់ដែលធ្វើឲ្យឆ្អិនក្រៀមខ្លាំងពេកនឹងជួបប្រទះកើតជំងឺមហារីកក្រពះច្រើនជាង អ្នកហូបសាច់ត្រឹមឆ្អិនល្មម (ឆ្អិនតែខាងក្រៅ) តែសាច់ខាងក្នុងនៅតែក្រហម ដូចនេះអ្នកដែលចូលចិត្តបរិភោគសាច់សត្វគ្រប់ប្រភេទរួមទាំងត្រីដែលអាំងឬចៀន ឲ្យឆ្អិនខ្លាំងពេកអាចជួបប្រទះនឹងជំងឺមហារីក្រពះអាហារកំរិតខ្ពស់ជាទីបំផុត ប៉ុន្តែខាងភ្នាក់ងារត្រួតពិនិត្យគុណភាពអាហាររបស់អង់គ្លេសក៏បានជាស់តឿនថា អ្នកបរិភោគអាហារគួរប្រយ័ត្នប្រយែងក្នុងការបរិភោគគឺ ការហូបអាហារឆ្អិនឬ អាហារឆៅច្រើនពេកក៏ជួបប្រទះនឹងកើតជំងឺបានដូចគ្នា៕

*(តមកពីទំព័រទី២៣)* កើតឡើងនៅក្នុងភូមិភាគដើមបូព៌ា តាមរយៈការដាក់បន្ទុបលទ្ធិប្រជាធិបតេយ្យឲ្យបណ្ដាប្រទេសក្នុងតំបន់នេះយកទៅអនុវត្តគឺថាធ្វើហាក់បីដូចជាប្រទេសប្រជាធិបតេយ្យមិនចេះធ្វើសង្គ្រាម និងមានតែប្រទេសកាន់អំណាចផ្ដាច់ការទេ ដែលចេះឈ្លោះប្រកែកគ្នា។ ក្រោយមកទៀត អាមេរិករបស់លោក Obama ចាប់ពីខែមករាឆ្នាំ២០០៩មក និងអឺរ៉ុបក៏នៅតែមិនអាចវិលមកស្និទ្ធស្នាលគ្នាខ្លាំងវិញ ដូចសម័យសង្គ្រាមត្រជាក់បានឡើយ ពីព្រោះអាមេរិកនៅសតវត្សរ៍ទី២១នេះ លែងចាត់ទុកអឺរ៉ុបថា ជាតំបន់ភូមិសាស្ត្រនយោបាយមួយសំខាន់ទៀតហើយ។ ហួតមកដល់ឆ្នាំ១៩៩១ ឆ្នាំដែលសហភាពសូវៀតរលាយនិងសង្គ្រាមត្រជាក់ត្រូវចប់ អឺរ៉ុបជាដង្ហើមរបស់អាមេរិក។ ចូរកុំភ្លេចថា អាមេរិកបានមកជួយស្រោចស្រង់អឺរ៉ុបប្រជាធិបតេយ្យឲ្យរួចពីអំណាចផ្ដាច់ការនៃចក្រភពអឺរ៉ុបកណ្ដាល មកជួយរំដោះអឺរ៉ុបឲ្យរួចពីក្រញាំAllemand nazi និងមកជួយការពារអឺរ៉ុបប្រជាធិបតេយ្យប្រឆាំងនឹងសហភាពសូវៀតកុម្មុយនិស្ត។

ឥឡូវនេះ នៅឆ្នាំ២០១០ អាមេរិករបស់លោក Obama បែរជាឲ្យតម្លៃទៅលើភូមិភាគដើមបូព៌ា និងអាស៊ីជាងទៅលើអឺរ៉ុបទៅវិញ។ ឲ្យតម្លៃទៅលើអាស៊ី ដោយហេតុតែការលេចត្រដែតឡើងលឿនរហ័សនៃប្រទេសចិនឲ្យតម្លៃទៅលើភូមិភាគដើមបូព៌ា ដោយហេតុតែជាជង្រុកនៃភេរវកម្ម និងជាចំណុចក្ដៅគគុកជាងគេ នៃអស្ថិរភាពពិភពលោកសព្វថ្ងៃ។ ម្យ៉ាងវិញទៀត អាមេរិករបស់Obama បែបមិនសង្ឃឹម មិនសង្ឃឹមថា សហភាពអឺរ៉ុបអាចក្លាយទៅជាមហាប្រទេសរួមគ្នាតែមួយ ដែលមានឥទ្ធិពលនយោបាយខ្លាំងក្លាអាចក្លាយជាគូប្រជែងឬជាដៃគូរបស់ខ្លួនបាន។

*ប្រភពពី RFI*

# អ៊ីស្រាអែលចង់ប្តូរឥរិយាបថក្នុងបញ្ហាអាណានិគមកិច្ច

មូលហេតុដែលនាំឲ្យរដ្ឋាភិបាលស្តាំនិយមអ៊ីស្រាអែលដែលឋិតនៅក្រោម ការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី Benyamin Netanyahu ធ្វើការប្តូរប្រែឥរិយាបថរបស់ខ្លួនក្នុងការសាងសង់លំនៅដ្ឋានថ្មី នៅតំបន់ Cisjordanie មកពីគេយល់ឃើញថាកាយវិការសម្របសម្រួលរបស់គេទាំងប៉ុន្មានដែលបានធ្វើទៅកាន់ភាគីប៉ាលេស្ទីន ហាក់ដូចជាគ្មានទទួលបានផលប្រយោជន៍អ្វីមកវិញសោះឡើយ។ ហេតុដូច្នេះហើយអ៊ីស្រាអែលធ្វើការព្រមានថាបើចាប់ពីពេលនេះទៅ១ខែឬ២ខែខាងមុខបើប្រសិនជាភាគីប៉ាលេស្ទីននៅតែពុំព្រមវិលមករកតុចរចាទេនោះ ភាគីអ៊ីស្រាអែលអាចនឹងសើរើមើលឡើងវិញនូវការផ្អាកឈប់សាងសង់លំនៅដ្ឋានថ្មី នៅតំបន់Cisjordanie បានសេចក្តីថាអ៊ីស្រាអែលនឹងបន្តធ្វើអាណានិគមកិច្ចរបស់ខ្លួន។



*លោកបេ៊ិនយ៉ាមីន នេតាន់យ៉ាហ៊ូ (BenjaminNetanyahu) នាយករដ្ឋមន្ត្រីអ៊ីស្រាអែល*

ចាប់តាំង ពីចុងខែវិច្ឆិកាឆ្នាំ២០០៩ រដ្ឋាភិបាលអ៊ីស្រាអែលបានប្រកាស ក្រោមសម្ពាធរបស់សហរដ្ឋអាមេរិកថា ខ្លួននឹងផ្អាកសម្រាប់រយៈពេល១០ខែក្នុងការសាងសង់លំនៅដ្ឋានថ្មីនៅ តំបន់Cisjordanie ក្នុងគោលបំណងជំរុញឲ្យមានកិច្ចចរចាដើម្បីស្វែងរកសន្តិភាពរវាង អ៊ីស្រាអែលនិងប៉ាលេស្ទីនដែលបានត្រូវផ្អាកហេតុតែមានសង្គ្រាមនៅតំបន់...... *(តទៅទំព័រទី២៩)*

# ហាងមាសមេគង្គ

## 湄江 MEKONG JEWELRY 珠寶



- **មានលក់មាសនិងពេជ្រគ្រប់ប្រភេទ**
- មានលក់គុជនិងត្បូងពេជ្រជាច្រើនសម្រាប់ធ្វើជាខ្សែក, ខ្សែដៃ, ក្រវិលនិងចិញ្ចៀន។ល។
- ទទួលរចនាគ្រឿងអលង្ការគ្រប់មុខគ្រប់ម៉ូដតាមការនិយមចូលចិត្តបែបបុរាណឬសម័យ។
- ទទួលជួសជុលគ្រឿងអលង្ការភ្លាមៗ !!!

សូមស្វាគមន៍អតិថិជនគ្រប់ទិសទី !!!

- **All Kinds of Diamonds & golds**
- COUNTLESS OF STYLES AVAILABLE FOR RINGS, NECKLACE, BRACELETS, ETC.
- WE ACCOMODATE ANY DESIGN THAT BEST SUITS YOUR INTERESTS.
- WE ARE MORE THAN HAPPY TO FIX OR REDESIGN YOUR PREOWNED JEWELRY.
- A VISIT TO OUR STORE WILL GUARANTEE YOUR SATISFACTIONS.

ADDRESS:
1954 ABORN ROAD
SAN JOSE, CA 95121

KIM
TEL: (408) 238-3377
FAX: (408) 238-2601

## ក្រុមហ៊ុនលក់សំបុត្រយន្តហោះ Travel Rose

- មានលក់សំបុត្រយន្តហោះក្នុងនិងក្រៅប្រទេស
- មានទទួលធ្វើទិដ្ឋាការទៅ អាស៊ី, អឺរ៉ុប, អូស្ត្រាលី និងប្រទេសផ្សេងៗនៅជុំវិញពិភពលោក។
- មានទទួលធ្វើលិខិតឆ្លងដែន។
- **Airline Ticket, Re-entry Permit, Visa, Passport**

*សូមអញ្ជើញទំនាក់ទំនងមកក្រុមហ៊ុនយើងខ្ញុំដោយមេត្រីភាព តាមអាស័យដ្ឋានដូចខាងក្រោម៖*

639 Tully Road Suite
San Jose, CA 95111
Tel: (408) 971-4530

*Travel Rose*
Travel &Tour
ANH(THANH)V0





*(តមកពីទំព័រទី២០)* ម្យ៉ាងទៀត ពួកគាត់មិនសូវមានលុយកាក់ ហើយក៏បានដាច់ចិត្តមិនត្រឡប់ទៅស្រុក។

លោកបន្ថែមទៀតថា អ្នកកៀសខ្លួនខ្លះគ្មានក្រដាសស្នាម មិនទាំងបានទៅកម្សាន្តសប្បាយនៅកន្លែងនានា នៅក្នុងប្រទេសកម្ពុជាផង កុំថាឡើយត្រឡប់ចូលទៅស្រុកកំណើត ៖ *«នៅបុណ្យចូលឆ្នាំនេះ ដូចជាយើងនៅជួបជុំក្នុងក្រុមគ្រួសារទៅស្រង់ទឹកនៅវត្ត។ ចូលឆ្នាំរួចហើយ ដល់ថ្ងៃឡើងស័ក្តិ ថ្ងៃទី១៦ យើងក៏ទាំងក្រុមគ្រួសារទាំងអស់ខ្មែរក្រោមហ្នឹងធ្វើជាចង្ហាន់ បង្សុកូលឲ្យខ្មោចជីដូនជីតាយើង។ ពេលនេះ យើងមិនបានទៅអ៊ីចឹងយើងនឹកស្រុកកំណើតដូចជាមិនទាន់ខាន។ ប៉ុន្តែយើងនៅតែគាំទ្រខ្មែរក្រោមជាមួយ ហើយយើងទៅមិនកើតទេ»*។

ប្រធានសមាគមព្រះសង្ឃខ្មែរក្រោម ព្រះតេជគុណ យឿង ស៊ិន និងជាសង្ឃរាជវត្តសាមគ្គីរង្សី ក្រុងភ្នំពេញ ដែលបានឃ្លាតពីស្រុកកំណើតយូរឆ្នាំណាស់មកហើយ មានព្រះថេរដីកាថា ម្នាក់ៗនឹកស្រុកកំណើតជាខ្លាំង ប៉ុន្តែការត្រឡប់ចូលទៅស្រុកដោយនាំយកទៅជាមួយនូវក្បួនតម្រានិងគម្ពីរក្បួនខ្នាតនានាត្រូវបានគេហាមឃាត់។ ព្រះអង្គថា សូម្បីតែមានការជានាដល់ទៅអាជ្ញាធរខ្មែរថែមទៀត ក៏វៀតណាមនៅតែមិនឲ្យចូលឡើយ។

ព្រះតេជគុណ យឿង ស៊ិន មានថេរដីកា ៖ *«ចម្រើនពរចង់តែចង់ណាស់ម្នាក់ៗ ចង់ទៅណាស់ តែមិនស្រួលច្បាប់ទៅវាសុទ្ធតែធ្វើទុក្ខ។ជាពិសេសបងប្អូនដែលគ្នាឡើងចង់បានរូបភាពដូចជាទស្សនាវដ្ដីឬប្រក្រតិទិនអីសម្រាប់មើលទៅតាមព្រំដែនគេឆែកយកអស់។ គេថាអក្សរខ្មែរគេឥតឲ្យចូលទេ។ ហើយមកសុំសៀវភៅធម៌ ទិញសៀវភៅធម៌ទៅគេយកអស់។ ដូចគ្នាសុំលិខិតឆ្លងដែន សុំដល់លោករដ្ឋមន្ត្រីក្រសួងធម្មការទៀតជានា នៅតែគេមិនឲ្យទៅទៀត»*។

វិទ្យុអាស៊ីសេរី បានព្យាយាមទាក់ទងស្ថានទូតវៀតណាមនៅកម្ពុជា ប៉ុន្តែគ្រប់លេខទូរស័ព្ទ មិនដំណើរការ។ យើងបានទូរស័ព្ទចូលបុរសជនជាតិវៀតណាមម្នាក់ ដែលក្នុងសៀវភៅរបស់ស្ថានទូតវៀតណាម បានសរសេរថា គាត់ជាមន្ត្រីផ្នែកព័ត៌មានរបស់ស្ថានទូត ប៉ុន្តែគាត់បានបដិសេធថា គាត់មិនមែននោះទេ។

បុរសដដែលបាននិយាយប្រាប់យើងថា ការរឹតត្បិតក្នុងការចូលទៅក្នុងប្រទេសវៀតណាម ជាការធម្មតាទេ សូម្បីតែជនជាតិវៀតណាម ក៏ត្រូវអាជ្ញាធរតាមដានមើលដែរ ៖ *«នេះជា រឿងធម្មតាទេសម្រាប់អ្នកធ្វើនយោបាយ ប៉ុន្តែបើសិនជាយើងមិនធ្វើនយោបាយ គឺជាអ្នករកស៊ីមិនជាអ្វីទេ។ សូម្បីតែខ្ញុំ ជាជនជាតិវៀតណាម ពេលដែលខ្ញុំទៅស្រុកកំណើត ក៏មានការតាមដានដូចជាប្រជាជនខ្មែរក្រោមដែលមករស់នៅទីនេះដែរ»*។

ថ្វីបើជនជាតិវៀតណាមគិតថា ការតាមដាន និងការរឹតត្បិតមកលើពលរដ្ឋខ្មែរក្រោម ដែលជាម្ចាស់ទឹកដីក្នុងការចូលទៅសួរសុខទុក្ខញាតិមិត្ត នៅរាល់ពេលពិធីបុណ្យទានថា ជាការធម្មតា ប៉ុន្តែអ្នកគោរពសិទ្ធិមនុស្សបានស្ដីបន្ទោសយ៉ាងខ្លាំងថា វៀតណាមកំពុងរំលោភបំពានទៅលើសិទ្ធិមនុស្ស ជាពិសេសសិទ្ធិនៃជនជាតិដើម ដែលទើបតែត្រូវអនុម័តដោយអង្គការសហប្រជាជាតិ៕ **ប្រភពពីវិទ្យុអាស៊ីសេរី**

---

***(តមកពីទំព័រទី៩)*** យ៉ាងជ្រាលជ្រៅចំពោះសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន ដែលបានចំណាយធនធាន និងពេលវេលាដ៏មានតំលៃជួយឧបត្ថម្ភគាំទ្រក្នុងការកសាងនូវសមិទ្ធិផលជាច្រើននៅវត្តខេមរង្សី ដើម្បីជាប្រយោជន៍ដល់ការលើកស្ទួយវិស័យព្រះពុទ្ធសាសនានិងសង្គមជាតិទាំងមូល។

ហេតុនេះ ព្រះសង្ឃ គណៈកម្មការ អាចារ្យវត្ត សូមប្រសិទ្ធិពរជ័យមហាប្រសើរជូនចំពោះពុទ្ធបរិស័ទទាំងអស់ ឱ្យទទួលបានសិរីសួស្តី ជ័យមង្គល អាយុយឺនយូរ សុខក្សេមក្សាន្ត និងប្រកបដោយពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ចូរកើតមានដល់លោក លោកស្រី ជានិច្ចនិរន្តរតរៀងទៅ៕ ដោយ ស៊ឹម សុរិយា

*(តមកពីទំព័រទី២៦)*ហ្កាហ្សា(ពីថ្ងៃ២៧ធ្នូដល់ថ្ងៃ១៨មករាឆ្នាំ២០០៩)។រដ្ឋាភិបាលស្តាំនិយមអ៊ីស្រាអែលដែលបិត នៅក្រោមការដឹកនាំរបស់លោកនាយក រដ្ឋមន្ត្រី Benyamin Netanyahu បានបន្ទន់ឥរិយាបថរបស់ខ្លួននិងបាន ធ្វើការសម្របសម្រួលបីយ៉ាង ទៅកាន់ភាគីប៉ាលេស្ទីន៖

ទី១-ការទទួលយល់ព្រមឲ្យមានរដ្ឋ ប៉ាលេស្ទីន។

ទី២- ការទទួលយល់ព្រមផ្អាកបញ្ឈប់បណ្តោះអាសន្នក្នុងការធ្វើ អាណានិគមកិច្ច។

ទី៣-បង្កើនគំនិតផ្តួចផ្តើមដើម្បីជំរុញឲ្យមានសន្តិភាពសេដ្ឋកិច្ចមានដូចជា(ការលើកចេញនូវរបាំងខាឃាំង ដែលមាននៅតាមផ្លូវ-ការជួយជំរុញឲ្យមានការបោះទុនធ្វើវិនិយោគដើម្បីជួយរុញច្រានឲ្យមានសន្ទុះសេដ្ឋកិច្ច)។ចំណែកឯរដ្ឋអំណាចប៉ាលេស្ទីនក្រោមការដឹកនាំរបស់លោកប្រធានMahmoud Abbas បានទាមទារជាបន្ទាន់ឲ្យភាគីអ៊ីស្រាអែលផ្អាកបញ្ឈប់ទាំងស្រុងការធ្វើអាណានិគមកិច្ចរបស់ខ្លួន ដែលក្នុងនោះមានតំបន់ Jérusalem ប៉ែក ខាងកើតផងដែរ។ ទាំងនេះជាថ្នូរប្តូរនឹងការបើកកិច្ចចរចារវាងប៉ាលេស្ទីននិង អ៊ីស្រាអែលដើម្បីស្វែងរកសន្តិភាព។

គួរកត់សម្គាល់ថា ក្រោយពីមានការខិតខំយ៉ាងស្វិតស្វាញរបស់លោក George Mitchell បេសកជនពិសេសអាមេរិក កិច្ចព្រមព្រៀងចរចាមិនចំពោះមួយរវាងអ៊ីស្រាអែល-ប៉ាលេស្ទីនក៏សម្រេចបាន។ ក៏ប៉ុន្តែកិច្ចចរចានេះបានទទួលបរាជ័យដោយហេតុតែអ៊ីស្រាអែលបានអនុញ្ញាតឲ្យបន្តធ្វើការសាងសង់១៦០០លំនៅដ្ឋានថ្មី នៅតំបន់Cisjordanieនាឱកាសទស្សនកិច្ចរបស់លោកអនុប្រធានាធិបតីអាមេរិកJoe Biden នៅថ្ងៃទី៩មីនាកន្លងទៅ។

ហេតុដូច្នេះហើយបានជានៅពេលថ្មីៗនេះ លោកស្រីប្រមុខការទូតអាមេរិកHillary Clinton បានអំពាវនាវឲ្យភាគីពាក់ព័ន្ធ ទាំងរដ្ឋាភិបាលស្តាំនិយមអ៊ីស្រាអែល ដែលបិតនៅក្រោមការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រី Benyamin Netanyahu ទាំងភាគីប៉ាលេស្ទីនខិតខំធ្វើការចរចាដោយក្តីស្មោះស្ម័គ្រ ដើម្បីស្វែងរកសន្តិភាពជូនប្រជាជនអ៊ីស្រាអែលក៏ដូចជាជូនប្រជាជនប៉ាលេស្ទីន ហើយនិងជូនប្រជាជនដើមបូព៌ា។ ក៏ប៉ុន្តែគោលបំណងដ៏ឧត្តុង្គឧត្តមនេះនឹងសម្រេចបាន លុះត្រាណាតែអ្នកដឹកនាំអ៊ីស្រាអែលមានសេចក្តីក្លាហានហ៊ានជ្រើសយកនយោបាយ និងមាគ៌ាថ្មីសម្រាប់ប្រទេសអ៊ីស្រាអែល៕

ប្រភពពី RFI

***(តមកពីទំព័រទី១៥)*** និងបទឧក្រិដ្ឋកម្មរបស់យួន ដែលបានធ្វើទៅលើខ្មែរក្រោមតាំងពីអតីតកាលរហូតមកទល់សព្វថ្ងៃនេះ ហើយថែមទាំងបានបង្ហាញមតិជាតិ និងអន្តរជាតិឲ្យកាន់តែច្បាស់នូវនយោបាយពុតត្បុតដ៏ល្ងង់ខ្លៅ នៃបក្សកុម្មុយនិស្តក្រុងយួននោះផងដែរ។ អាស្រ័យហេតុនេះ យើងយល់ឃើញថា វាសនាខ្មែរក្រោមនៅពេលឆាប់ៗខាងមុខនេះ នឹងទទួលបាននូវសិទ្ធិសេរីភាពនិងសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ពីរបបអាណានិគមយួនជាក់ជាមិនខាន ព្រោះយើងមានសហព័ន្ធខ្មែរកម្ពុជាក្រោមជាអាវុធដ៏មុតស្រួច ធ្វើការតវ៉ាតាមច្បាប់អន្តរជាតិដោយសន្តិវិធីនិងដោយគតិបណ្ឌិតនោះ ៕

ដោយ *VOKK*


## *ប្រេងខ្យល់ប្រទាលខ្មែរបុរាណ*

**វិធីប្រើ៖** លាបនៅពេលដែលចុកដៃជើង, ស្ពឹកស្រពន់, ចុកចង្កេះ, ថ្លោះគ្រិច, ឈឺក្បាល, វិលមុខ, ពុលឡាន ពុលកាណូត, ពុលយន្តហោះ, ចុកពោះ, ធ្លល់ពោះ, ហើមពោះ, ណែនពោះ, តឹងច្រមុះ, ផ្តាសាយ, មូសខាំ, ក្អែកខាំ ស្រាំងទិច, ឱម៉ាលទិច, ឡើងកន្ទួល, រម៉ាស់ផ្សេងៗ.......។ **បញ្ជាក់៖** *ហាមយកប្រេងខ្យល់នេះទៅលាបភ្នែក។*

***លោក អ្នក ចង់បានប្រេងខ្យល់ប្រទាលខ្មែរបុរាណ សូមទំនាក់ទំនងទូរស័ព្ទលេខ៖ (408) 923-2166***

# ស្រណោះដីខ្មែរ

ខ្ញុំសែនស្រណោះ អាល័យអាឡោះ មាតុភូមិខ្ញុំ
សម្បត្តិធម្មជាតិ សំបូរស្តុកស្តម្ភ អាចរស់សុខុម
ឧត្តមប្រពៃ។

តែអនិច្ចា កម្មកាច់ឫស្យា វាសនាចង្រៃ
ត្រូវគេឈ្លានពាន យាយីពេកក្រៃ រាប់ខែឆ្នាំថ្ងៃ
ភិតភ័យខ្លោចផ្សា។

ទឹកដីអង្គរ ប្រសើបវរ តំណដូនតា
ខ្ញុំសែនអាណិត ដួងចិត្តខ្លោចផ្សា ស្រក់ទឹកនេត្រា
អនិច្ចាទុក្ខខ្មែរ។

ទន្លេបឹងបួរ ស្ទឹងអូរបង្គួរ សមុទ្រផងដែរ
ត្រីទន្លេសាប មាស ស ផងខ្មែរ ឥឡូវនេះបែរ
ជាខ្សត់ទៅវិញ។

តើត្រីទៅណា ឆ្លងដែនសីមា សែនទុក្ខទោម្នេញ
មិនផ្តល់ឱ្យខ្មែរ បរិភោគពេញលេញ និយាយលែងចេញ
ពោរពេញមូរហ្មង។

ខ្មែរកាន់យួនក្តាប់ រដ្ឋអំណាចច្បាប់ ខ្មែរយួនចម្បង
ជាគ្រូអាចារ្យ ឧបជ្ឈាយ៍ធ្វើបង ប្រៀនប្រដៅផង
ខ្មែរត្រង់ខ្មែរត្រាប់។

បំណុលខ្មែរអើយ សងពុំចេះហើយ សងទាល់តែស្លាប់
អស់ទឹកអស់ដី អស់ព្រៃចំណាប់ បាតក្រឡផ្កាប់
ប្រញាប់ដឹងខ្លួន។

ត្រីងៀតឆ្អៀតពង គៀងបញ្ចូលសឹង ធ្លាក់ផ្លងមងយួន
មងធំក្រាស់ក្រែល ដាក់ត្រីធំធួន ខ្មែរអើយភ្ញាក់ខ្លួន
យួនអសិរពើស។

ផ្អែមក្រៅផៅក្នុង ខ្មែរណាដែលស្លុង ប្រុងជាប់គន្លឹះ
យួនលើកបន្តុប គៀបជាប់លែងអ៊ឹះ យួននៅពេញទិស
គ្មានអ៊ឹះពេញស្រុក។

ពេលណាយួនចេញ យួនមិនចំណេញ យួនរស់ស្រណុក
រស់នៅដីខ្មែរ សម្បត្តិសម្បុក ធម្មជាតិគ្រប់មុខ
យួនសុខលែងភ័យ។

យួនពុំចេញឡើយ សុខប៉ុណ្ណេះហើយ រំភើយចិត្តក្រៃ
យកលេសជួយខ្មែរ ជួយគ្រប់វិស័យ គ្រូយួនជួយថ្វៃ
ឱ្យន័យស្រុកខ្មែរ។

បើខ្មែរមានភ័ព្វ កម្ពុជាមិនងាប់ ខ្មែរតស៊ូដែរ
កម្លាំងសាមគ្គី ប្រយុទ្ធឥតបែរ វីរៈជនខ្មែរ
អ្នកស្នេហាជាតិ៕

*ដោយអ្នកគ្រូ សុផានី បៃ*

# រាសីប្រចាំខែឧសភា

**១.ឆ្នាំជូត:** រាសីខែនេះល្អមធ្យម។ ការប្រកបកិច្ចការងារពុំបានទទួលផលល្អឡើយ។ ចំណែកការធ្វើដំណើរត្រូវប្រយ័ត្នបន្តិចទើបបានសុខ។ រីឯការរស់នៅវិញ លោកអ្នកមានភាពប្តូរផ្លាស់ច្រើន ជូនកាលត្រូវរ៉ូវគ្នា ជួនកាលទាស់ទែងគ្នា។

**២.ឆ្នាំឆ្លូវ** រាសីខែនេះល្អមធ្យម។ ការប្រកបរបរជួញដូរមានភាពពុំសូវកាក់កបទេ។ ការធ្វើដំណើរផ្លូវឆ្ងាយប្រព្រឹត្តទៅជាធម្មតា តែត្រូវមានស្មារតីរឹងប៉ឹងកុំជឿសម្តីអ្នកដទៃខ្លាំងពេក។ជីវិតរស់នៅមានការមិនចុះសម្រុងនឹងគ្នាទេ។

**៣.ឆ្នាំខាល** រាសីខែនេះស្រុតចុះ។ ការប្រកបរបររកស៊ីផ្សេងៗទទួលផលជាមធ្យម។ ការធ្វើដំណើរកំសាន្តត្រូវមានការប្រុងប្រយ័ត្នខ្ពស់។រីឯជីវិតរស់នៅក្នុងសង្គមគ្រួសារវិញ មិនសូវមានភាពរុះរាយនិងយល់ចិត្តគ្នាទេ ហើយជួបការរអាក់រអួលផ្លូវចិត្តច្រើន។

**៤.ឆ្នាំថោះ** រាសីខែនេះល្អមធ្យម។ រយៈពេលនេះ កិច្ចការងារណាដែលបំពេញខ្លួនឯងបានគួរខិតខំឲ្យអស់ពីកំលាំងកាយចិត្តនឹងទទួលបានផលល្អ។ ដំណើរចាកចេញក្រៅផ្ទះត្រូវប្រកាន់ចិត្តឲ្យនឹងធឹងមានគេព្យាបាទ តែពុំបានសំរេចទេ។ ចំពោះការរស់នៅមានដំណើរថយក្រោយច្រើន។

**៥.ឆ្នាំរោង** ដួងរាសីខែនេះខ្ពស់ត្រដែត។ បើជាអ្នកប្រកបរបររកស៊ីជួញដូរទទួលជោគជ័យច្រើន អាចប្រមូលបានផលគួរជាទីគាប់ចិត្ត។ ការធ្វើដំណើរជិតឆ្ងាយមានភាពសុខសាន្ត។ រីឯសេចក្តីស្នេហាវិញពុំសូវល្អទេ ច្រើនជួបបញ្ហាក្នុងសង្គមគ្រួសារ។

**៦.ឆ្នាំម្សាញ់** រាសីខែនេះល្អបង្គួរ។ ចំពោះការប្រកបរបរជួញដូរប្រាក់ចំណូលរកបានសមល្មម។ បើការចេញដំណើរផ្លូវឆ្ងាយត្រូវប្រុងប្រយ័ត្នបន្តិចក្រែងជួបគ្រោះថ្នាក់។ រីឯការរស់នៅក្នុងសង្គមគ្រួសារវិញមានការអធ្យាស្រ័យគ្នាទៅវិញទៅមកបានច្រើន។

**៧.ឆ្នាំមមី** រាសីខែនេះល្អជាមធ្យម។លោកអ្នកប្រកបការងារពុំសូវទទួលផលល្អទេ បើចង់បោះទុនរកស៊ីត្រូវប្រយ័ត្នបន្តិចព្រោះមានការខាតបង់ច្រើន។ បញ្ហាសង្គមគ្រួសារវិញនោះមានដំណើរថយក្រោយបន្តិចនិងចាប់កំហុសគ្នាខ្លះៗ។

**៨.ឆ្នាំមមែ** រាសីខែនេះស្រុតចុះ។ ការជួញដូរផ្សេងៗប្រាក់ចំណូលមានការខ្សត់ខ្សោយបន្តិច ដូច្នេះលោកអ្នកត្រូវតែខិតខំប្រឹងប្រែង។ ចំពោះការធ្វើដំណើរវិញប្រយ័ត្នឧបទ្ទុតិហេតុយាយី។ ចំណែកការរស់នៅមានការខ្វល់ខ្វាយ ព្រោះតែគិតម្នាក់ឯងច្រើនពេក។

**៩.ឆ្នាំវក** ដួងរាសីខែនេះល្អមធ្យម។ ចំពោះលោកអ្នកប្រកបរបររកស៊ីទទួលបានផលល្អ។ ការធ្វើដំណើរផ្លូវឆ្ងាយពុំសូវមានសុវត្ថិភាពទេ ប្រយ័ត្នឧបទ្ទុតិហេតុកើតឡើង។ ចំណងអាពាហ៍ពិពាហ៍វិញនោះ មានការប្រែប្រួលមិនទៀងទាត់ទេ ត្រូវចេះអត់ឪនឱ្យគ្នាទៅវិញទៅមក។

**១០.ឆ្នាំរកា** រាសីខែនេះល្អបង្គួរ។ ដំណើរជីវិតប្រកបទៅមុខមិនមានការផ្លាស់ប្តូរទេ។ ចំពោះការប្រកបរបររកស៊ីជួញដូរមានភាពរស់រវើកឡើងវិញ ទទួលបានប្រាក់ចំណេញ សមគួរ។ចំពោះការរស់នៅមានដំណើរជឿនលឿនទៅមុខបង្គួរ។

**១១.ឆ្នាំច** រាសីខែនេះល្អជាមធ្យម។ ការធ្វើដំណើរចាកចេញទៅក្រៅផ្ទះលោកអ្នកមានសុវត្ថិភាពល្អញាតិមិត្តរាប់អាន។ រីឯការរកទទួលទានវិញគឺបានផលជាធម្មតា។ ចំណែកការរស់នៅលោកអ្នកនឹងមានសុភមង្គលល្អក្នុងសង្គមគ្រួសារ។

**១២.ឆ្នាំកុរ** រាសីខែនេះល្អបង្គួរ។ សំរាប់លោកអ្នកប្រកបរបររកស៊ីទទួលបានផលចំណេញគួរសម។ ការធ្វើដំណើរជិតឆ្ងាយគ្មានអ្វីជាឧបសគ្គទេតែត្រូវប្រយ័ត្នបន្តិច ។ចំណែកក្នុងរង្វង់គ្រួសារមានភាពរីកចំរើននិងជឿនលឿនទៅមុខ កំពុងបើកទំព័រជីវិតថ្មីសម្រាប់លោកអ្នកហើយ។

# បុណ្យចូលឆ្នាំថ្មី ឆ្នាំខាល ទោស័ក ព.ស ២៥៥៤ វត្តខេមររង្សី ក្រុងសាន់ហូស្សេ រដ្ឋកាលិហ្វ័រញ៉ា




















